សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចាត់ចែងរក្សាការពារ ក្នុងសំណុំរឿងរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **កញ្ញា. ផន ផាណា**

**កញ្ញា. យឹម លីណា**

សាស្ត្រាចារ្យណែនាំ

**លោកស្រីសាស្ត្រាចារ្យ ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំសិក្សា ២០១៦

ជំនាន់ទី២០

ឆ្នាំសរសេរសារណា២០២០

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ផន ផាណាវី** និងឈ្មោះ **ឃឹម លីណា** ជានិស្សិតផ្នែកបរិញ្ញបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០១៩-២០២០។

ជាបឋមនាងខ្ញុំសូមសម្ដែងនូវគារវកិច្ចគោរពដឹងគុណយ៉ាងជ្រាវជ្រៅជាទីបំផុតចំពោះលោកអ្នកមានគុណទាំងគឺៈ

១. លោកឪពុក **ចេវ សុផន** និងអ្នកម្ដាយ **ថៃ ចំណាន**

២. លោកឪពុក **ហ៊ុន ចិន្ដា** និងអ្នកម្ដាយ **ថៃ ស៊ីនួន**

៣. លោកឪពុក **គឹម សុខា** និងអ្នកម្ដាយ **លី ចន្ធូ**

សូមសម្ដែងសេចក្ដីគោរព និងការដឹងគុណ ចំពោះការខិតខំប្រឹងប្រែងប្រកបដោយព្រហ្មវិហារធម៌ ចិញ្ចឹមបីបាច់ថែរក្សាខិតខំអស់កម្លាំងកាយចិត្តប្រឹងប្រែងអប់រំប្រៀនប្រដៅជួយជ្រោមជ្រែងក៏ដូចជាជួយជម្រុញអោយនាងខ្ញុំទាំងពីរទទួលបាននូវចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូអ្នកគ្រូសាស្ត្រចារ្យគ្រប់ៗរូប** ដែលបានខិតខំប្រឹងប្រែងនិងប្រឹងអស់ពីសមត្ថភាពក្នុងការដឹកនាំ ក្នុងគោលបំណងបណ្ដុះបណ្ដាលមូលធនផ្នែកបញ្ញាធនធានមនុស្សកម្ពុជាអោយមានចំណេះដឹងបទពិសោធន៍នឹងមានសមត្ថភាពខ្ពស់ដើម្បីក្លាយជាសសរទ្រូងស្របតាមកាលានុវត្តភាពនៃការអភិវឌ្ឍន៍របស់ប្រទេសជាតិ។

សូមគោរពថ្លែងអំណរគុណចំពោះ **លោកស្រីសាស្ត្រាចារ្យ ម៉ុយ ធីតា** ដែលបានខិតខំប្រឹងប្រែងណែនាំ អប់រំ ចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត ចែករំលែកចំណេះដឹង ជាមួយនឹងការដឹកនាំ កែលម្អចង្អុលបង្ហាញ ទម្រង់ទិសព្រមទាំងចែករំលែកនូវវិធីសាស្ត្រល្អៗ និងផ្ដល់យោបល់ល្អៗដែលទាក់ទងនឹងប្រធានបទសារណារបស់ពួកនាងខ្ញុំ រួមទាំងចំណាយពេលវេលាដ៏មានតម្លៃតាំងពីចាប់ផ្ដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ។

សូមគោរពថ្លែងអំណរគុណលោកពូអ្នកមីង ដែលជួយទំនុកបម្រុងជាប្រាក់ក្ដីជាកន្លែងស្នាក់នៅក្ដីដល់យើងខ្ញុំព្រមទាំងជួយទាំងកម្លាំងកាយ និងកម្លាំងស្មារតីដើម្បីឱ្យយើងខ្ញុំបានរៀនសូត្រយកចំណេះដឹងទាំងឡាយរហូតដល់បញ្ចប់ថ្នាក់បរិញ្ញបត្រនេះ។

ជាចុងបញ្ចប់នាងខ្ញុំទាំងពីរសូមបួងសួងដល់វត្ថុសាកសិទ្ធិទាំងឡាយទាំងពួង ដែលមានបារមីនៅលើលោកយើងនេះសូមមេត្តាតាមបីបាច់ថែរក្សាអ្នកមានគុណទាំងពីរ ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការនៃសាកលវិទ្យាល័

យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកពូ អ្នកមីង បងប្អូន និងមិត្តភក្តិទាំងអស់ សូមឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាត។

# អារម្ភកថា

បន្ទាប់ពីទទួលបាននូវការសិក្សាស្វែងយល់នូវទ្រឹស្តីផ្នែកនីតិសាស្រ្តនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមកនេះយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពីសំណាក់សាស្រ្តចារ្យ តាំងពីឆ្នាំសិក្សាមូលដ្ឋាន រហូតមកដល់ពេលនេះ។ ចំពោះមូលហេតុនៃការជ្រើស យកប្រធានបទស្តីពី នីតិវិធីចាត់ចែងរក្សាការពារ នេះមកធ្វើការស្រាវជ្រាវ គឺដោយសារតែប្រធានបទនេះមើលទៅមានភាពសាមញ្ញ ប៉ុន្តែបើសិក្សាអោយស៊ីជម្រៅវិញ វាពិតជាមានភាពស្មុគស្មាញយ៉ាងខ្លាំង។ សារណានេះត្រូវបានចងក្រងឡើងសម្រាប់ទុកជាឯកសារសម្រាប់សិស្ស និស្សិត ឬ អ្នកដែលមានបំណងចង់ស្វែងយល់បន្ថែមអំពីប្រធានបទនេះផងដែរ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី យើងខ្ញុំមិនអាចអះអាងថាការស្រាវជ្រាវនេះ គ្មានចំណុចខ្វះខាត ឬ ចន្លោះប្រហោងឡើយ ហេតុដូច្នេះប្រសិនបើមាននូវកំហុសមួយចំនួនដែលកើតមាននៅក្នុងកិច្ចការនេះ សូមមេត្តាផ្តល់នូវគំនិតរិះគន់ក្នុងន័យស្ថាបនាដល់យើងខ្ញុំផង។

ជាទីបញ្ចប់យើងខ្ញុំពិតជាមានសេចក្តីរំភើបយ៉ាងខ្លាំងដែលបានចងក្រងនូវសារណានេះឡើង ហើយក៏សង្ឃឹមយ៉ាងមុតមាំថា វាជាចំណែកមួយសម្រាប់ការសិក្សាស្រាវជ្រាវទាំងអស់ជាពិសេសគឺ សិស្ស-និស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្រ្តនេះផ្ទាល់តែម្តង។

ដើម្បីស្ថាបនាស្នាដៃមួយនេះឱ្យបានល្អ ក៏ដូចជាជំនួយដល់ការបង្កើតស្នាដៃក្រោយៗឱ្យកាន់តែល្អឥតខ្ចោះ យើងខ្ញុំរីករាយទទួលយកនូវរាល់ការផ្តល់មតិយោបល់ និងការរិះគន់ទាំងឡាយពី លោកគ្រូ អ្នកគ្រូ និងសំណាក់អ្នកអានគ្រប់មជ្ឈដ្ឋាន។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម ........................................................................................................ ១**

## ជំពូកទី១

## សញ្ញាណទូទៅនៃនីតិវិធីចាត់ចែងរក្សាការពារ

**ផ្នែកទី១៖ បទដ្ឋានគតិយុត្តនៃការចាត់ចែងរក្សាការពារ ............................................. ៤**

១. គោលបំណងនៃការចាត់ចែងរក្សាការពារ ........................................................ ៥

២. វិសាលភាពនៃការចាត់ចែងរក្សាការពារ ........................................................ ៥

៣.មូលហេតុនៃការស្នើសុំរក្សាការពារ ........................................................ ៦

**ផ្នែកទី២៖ ប្រភេទនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី ..................៧**

១. ការរឹបអូសបណ្តោះអាសន្ន ........................................................ ៧

២. ការចាត់ចែងរក្សាការពារបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ........................ ៨

ក. ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរកាន់កាប់ ........................ ៩

ខ.ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ........................ ៩

៣ .ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន ........................ ៩

**ផ្នែកទី៣៖ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ........................................ ១០**

១. លក្ខណៈបណ្តោះអាន្ន........................................................១០

២ .លក្ខណៈបន្ទាន់បង្ហំ ........................................................១០

៣. លក្ខណៈបន្ទាប់បន្សំ ........................................................១០

៤ . លក្ខណៈសម្ងាត់ ........................................................១០

**ផ្នែកទី៤៖ ដែនសមត្ថកិច្ចនៃនីតិវិធីចាត់ចែងរក្សាការពារ ដែនសមត្ថកិច្ចតុលាការ ....១១**

## ជំពូកទី២

## យន្តការនៃការចាត់ចែងរក្សាការពារ

**ផ្នែកទី១ នីតិវិធីក្នុងការសុំចេញដីការសម្រេចចាត់ចែងរក្សាការពារ**.......................... ១៣

១. ការសុំដីការសម្រេចចាត់ចែងរក្សាការពារ ........................................................ ១៣

ក. អត្តសញ្ញាណ និង អាសយដ្ឋាននៃគូភាគី ........................................................ ១៣

ខ. អន្តន័យនៃនៃការសម្រេចដែលសុំអោយតុលាការចេញ ........................................១៤

គ. ទំនាក់ទំនងគតិយុត្តនៃការដាក់រក្សាការពារ........................................................១៤

ឃ. ភាពចាំបាច់នៃការដាក់រក្សាការពារ ........................................................១៤

ង. ភស្តុតាងបញ្ជាក់ ..................................... ១៥
២ . ដែនសមត្ថកិច្ច ..................................... ១៥
ក.តុលាការដែលមានសមត្ថកិច្ចចំពោះការរឹបអូសជាបណ្តោះអាសន្ន ..................................... ១៥
ខ.តុលាការដែលមានសមត្ថកិច្ចចំពោះការចាត់ចែងជាបណ្តោះអាសន្ន ..................................... ១៥
គ.ការបង់ពន្ធ ..................................... ១៦
ឃ.សេចក្តីវិនិច្ឆ័យរបស់តុលាការ ..................................... ១៦
៣ . កម្មវត្ថុនៃការវិនិច្ឆ័យ ..................................... ១៦
៤ .វិធីនៃការវិនិច្ឆ័យ ..................................... ១៧
**ផ្នែកទី២៖ ប្រភេទនៃការចេញដីកាសម្រេចរក្សាការពារ** ..................................... ១៧
១ . ដីការឹបអូសជាបណ្តោះអាសន្ន ..................................... ១៧
ក. ការដាក់ប្រាតិភាគ ..................................... ១៨
ខ. ខ្លឹមសារ ..................................... ១៨
គ. ភាពចាំបាច់ ..................................... ១៨
ឃ. នីតិវិធីនៃការចេញដីកាសម្រេច ..................................... ១៩
២. ដីកាសម្រេចចាត់ចែងបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ..................................... ២០
ក.ខ្លឹមសារ ..................................... ២០
ខ.ភាពចាំបាច់ ..................................... ២០
គ. នីតិវិធីនៃការចេញដីកាសម្រេច ..................................... ២១
៣. ដីកាសម្រេចចាត់ចែងបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ..................................... ២១
ក. ខ្លឹមសារ ..................................... ២១
ខ. ភាពចាំបាច់ ..................................... ២១
គ. នីតិវិធីនៃការចេញដីកាសម្រេច ..................................... ២២
៤ .ដីកាសម្រេចលើកចោលពាក្យសុំ ..................................... ២២
**ផ្នែកទី៣៖ ការអនុវត្តដីកាសម្រេច** ..................................... ២២
១ .លក្ខខណ្ឌក្នុងការអនុវត្ត ..................................... ២២
២ .ពាក្យសុំអនុវត្តដីកាសម្រេចចាត់ចែងរក្សាការពារ ..................................... ២៣
៣. ពន្ធនៃពាក្យសុំអនុវត្ត ..................................... ២៤
៤ .ស្ថាប័នមានសមត្ថកិច្ច ..................................... ២៤
ក. អាជ្ញាសាលា ..................................... ២៤

ខ. តុលាការអនុវត្ត.......... ២៥
៥ . ការរឹបអូសជាបណ្ដោះអាសន្ន.......... ២៥
ក.ចលនវត្ថុ និង អចលនវត្ថុ .......... ២៥
ខ.សិទ្ធិលើបំណុល និងទ្រព្យសម្បត្តិ.......... ២៨
គ. នាវា .......... ២៨
៦ .ការចាត់ចែងជាបណ្ដោះអាសន្ន .......... ៣០
ក. ប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន.......... ៣០
ខ. លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ .......... ៣០
គ. ល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន.......... ៣១
៧ .ការអនុវត្ត .......... ៣១

## ជំពូកទី៣

## ឧបាស្រ័យលើដីកាសម្រេចរក្សាការពារ

**ផ្នែកទី១៖ ការតវ៉ាដីកាសម្រេចរក្សាការពារ** .......... ៣៤
១ .នីតិវិធីនៃការតវ៉ាដីកាសម្រេច .......... ៣៥
ក. ការដាក់ពាក្យសុំតវ៉ា.......... ៣៥
ខ. ការទាញហេតុផលផ្ទាល់មាត់ .......... ៣៥
គ. ដីកាសម្រេចការសុំតវ៉ាលើដីកាសម្រេចរក្សាការពារ.......... ៣៥
២ .ការលុបចោលដីកាសម្រេច .......... ៣៦
ក. មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ .......... ៣៦
ខ. ការទាញហេតុផលផ្ទាល់មាត់ .......... ៣៨
គ. ផ្អាកបណ្ដោះអាសន្ន .......... ៣៨
ឃ. អានុភាពនៃដីកាដែលសម្រេចលុបចោលដីកាសម្រេច.......... ៣៩
៣.ការអនុវត្ត.......... ៤០
ក. បុគ្គលដែលមានទំនាក់ទំនងគតិយុត្ត.......... ៤០
ខ. សមត្ថកិច្ច/អាជ្ញាធរ.......... ៤១
គ. ផ្អាកបណ្ដោះអាសន្ន .......... ៤១
ឃ. ដីកាសម្រេច.......... ៤១
៤ .បណ្ដឹងជំទាស់.......... ៤២
ក. ការទាញហេតុផលផ្ទាល់មាត់ .......... ៤២

ខ. ដីកាសម្រេច ........................................................................................ ៤២
**សេចក្តីសន្និដ្ឋាន**........................................................................................ ៤៤
**អនុសាសន៍**........................................................................................ ៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១

# សញ្ញាណទូទៅនៃនីតិវិធីចាត់ចែងរក្សាការពារ

## ផ្នែកទី១៖ បទដ្ឋានគតិយុត្តនៃការចាត់ចែងរក្សាការពារ

ព្រះរាជាណាចក្រកម្ពុជាមានការវិវត្តន៍ជាច្រើនពីច្បាប់ប្រពៃណីដែលមិនរសរសេរ តាំងពីសម័យអង្គរមក ជាច្បាប់សរសេរដែលត្រូវអនុម័តដោយស្ថាប័ននីតិបញ្ញត្តិដែលពាក់ព័ន្ធ។ ប្រព័ន្ធច្បាប់នៅក្នុងប្រទេស កម្ពុជាជះឥទ្ធិពលជាខ្លាំងពីប្រពន្ធ័ច្បាប់ស៊ីវិលរបស់ប្រទេសបារាំងនៅក្រោមអាណានិគមពីឆ្នាំ ១៨៦៣ ដល់ ១៩៥៣ និង រហូតដល់ ១៩៧៥។ នៅក្រោមរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ខែ មេសា ទៅដល់ខែ មិថុនាឆ្នាំ១៩៧៩ប្រពន្ធ័ច្បាប់របស់ប្រទេសកម្ពុជាទាំងមូលទាំងច្បាប់ដែលមានស្រាប់ដូចជាច្បាប់របស់រដ្ឋាភិបាលនិងច្បាប់គ្រប់គ្រងប្រពន្ធ័យុត្តាធិការត្រូវ បានបំភ្លេចបំផ្លាញ។

ការចាត់ចែងរក្សាការពារតាមនីតិវិធីចាស់ មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេ តែត្រូវបានបង្កើតតាមការ អនុវត្តជាក់ស្តែងចេញពីកថាខណ្ឌស្តីពី "វិធានការបណ្តោះអាសន្ន" នៃសារាចរលេខ ០៤ សរច ៨៤ ឆ្នាំ ១៩៨៤ របស់ក្រសួងយុត្តិធម៌។ ប៉ុន្តែខ្លឹមសារ និង នីតិវិធីនៃ "វិធានការបណ្តោះអាសន្ន" ដែល មានចែងនៅក្នុងកថាខណ្ឌនោះមិនមានភាពច្បាស់លាស់ទេ។ ដោយសារនៅក្នុង "វិធានការបណ្តោះអាសន្ន" ក្នុងរឿងរដ្ឋប្បវេណី រួមមាន: ដីកាសម្រេចតាមពាក្យសុំ[1] , ដីការសម្រេចកិច្ចការប្រញាប់[2] , ដីកាបំបែកលំនៅដ្ឋាន ជាដើម ។ ក្នុងករណីចៅក្រមពេលទទួលពាក្យបណ្តឹង រហូតដល់ពេលជំនុំជម្រះ ចៅក្រមមានសិទ្ធិចេញដីកាសម្រេច ជាប្រញាប់ តាមសំណូមពររបស់គូភាគី ប្រសិនបើយល់ថាជាចាំបាច់។ ដីកាសម្រេចនេះមានគោលដៅ ការពារការអន្តរាយផ្សេងៗ ដែលអាចកើតមានជាយថាហេតុ។ ដីកាសម្រេចកត់ត្រាទ្រព្យសម្បត្តិ និង ប្រគល់សិទ្ធិ ដល់ជនណាម្នាក់ឱ្យថែរក្សាជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិ ដែលមានទំនាស់ដើម្បីការពារផល ប្រយោជន៍របស់គូភាគី [3]។

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើក្នុង ឆ្នាំ ២០០៦ គន្លឹទី៧ បានចែងនូវបទប្បញ្ញត្តិលម្អិត ស្តីពីការចាត់ចែងរក្សាការពារ ដោយឈរលើគោលគំនិតនៃភាពច្បាស់លាស់នៃនីតិវិធី និង ខ្លឹមសារនៃ ការចាត់ចែងរក្សាការពារ ជាការអនុវត្តដ៏សមរម្យមួយដែលត្រូវយកបញ្ញត្តិ នៃក្រមនីតិវិធីរដ្ឋប្បវេណីទៅ អនុវត្ត[4]។ ប៉ុន្តែនីតិវិធីនៃ

---

1 ទំព័រទី ២៧ នៃអត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណីរបស់ លោក ហ៊ីង ធីឬទ្ធី ឆ្នាំ ២០០៧(ពាក្យពីដើមត្រូវបានគេហៅថា "ដីកាចារលើពាក្យ" ជាប្រភេទសេចក្តីសម្រេចមុនអង្គសេចក្តី គូភាគីអាចស្នើសុំទៅតុលាការ បានគ្រប់ពេលវេលា ដើម្បីឱ្យតោលាការចេញសេចក្តីសម្រេចតាមពាក្យសុំនេះ )។

2ទំព័រទី ៣១ នៃអត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណីរបស់ លោក ហ៊ីង ធីឬទ្ធី ឆ្នាំ ២០០៧(ជាប្រភេទដីកាទប់ស្កាត់ការការពារដូចដីការសម្រេចតាមពាក្យស្នើសុំដែរ តែដីកាប្រញាប់នេះតុលាការកោះហៅ គូភាគីទាំងពីរមកសាកសួរ។

3 ទំព័រទី ២២ នៃអត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណីរបស់ លោក ហ៊ីង ធីឬទ្ធី ឆ្នាំ ២០០៧

4 ទំព័រទី ២២៣ សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ នៃព្រះរាជាណាចក្រកម្ពុជា

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដ៏ស្មុគស្មាញដែលរួមបញ្ចូលទាំងនីតិវិធីនៃការសម្រេចសេចក្ដីផង និង នីតិវិធីការអនុវត្តចាស់(វិធានការបណ្ដោះអាសន្ន) នៃសារាចរលេខ ០៤ សរច ៨៤ ឆ្នាំ ១៩៨៤ ចេញដោយក្រសួងយុត្តិធម៌ ។

## ១. គោលបំណងនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងរក្សាការពារ និង ថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ ដើម្បីរក្សាគោលបំណងរបស់បុគ្គលណាម្នាក់នៅពេលដែលមានការបារម្ភថាការអនុវត្ត ដោយបង្ខំនឹងមិនអាចធ្វើបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួល ស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ នៅពេលដែលមានបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ[5]។ មិនត្រឹមតែជាច្បាប់ជាទម្រង់ប៉ុណ្ណោះទេ សូម្បីតែច្បាប់សារជាតុ ក៏បានជួយធ្វើការអន្តរាគមន៍ផងដែរ ក្នុងការការពារសិទ្ធិនិងផលប្រយោជន៍របស់ម្ចាស់បំណុល ក្នុងករណីដែលកូនបំណុលចង់យកទ្រព្យសម្បត្តិដែលមាននោះគេចវេសពីការអនុវត្តដោយបង្ខំដោយការឃុបឃិត គ្នាជាមួយ និងតតិយជន ក៏ត្រូវចាត់ទុកជាមោឃៈដែរ។ ផ្ទុយទៅវិញបើតតិយជននោះជាសុចរិតម្ចាស់បំណុលក៏មិនអាចអះអាងចំពោះតតិយជននោះបានដែរ[6]។ ត្រង់ចំណុចនេះហើយដែលធ្វើម្ចាស់បំណុលជ្រើសរើសយកនីតិវិធីចាត់ចែងរក្សាការពារ ដែលមធ្យោបាយដែលល្អមួយដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់ខ្លួន។នៅពេលដែលមានបណ្ដឹងអង្គសេចក្ដីដែលត្រូវបានចាត់ការនោះគឺត្រូវចំណាយពេលវេលាមួយវែងដែលមិនអាចកំណត់បាន ដូច្នេះនៅអំឡុងពេលនៃនីតិវិធីអង្គសេចក្ដីនេះពេលខ្លះម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍ដោយសារតែចេតនាទុច្ចរិតរបស់កូនបំណុលដែលលាក់ទុកទ្រព្យ សម្បត្តិរបស់ខ្លួនតាមរយៈការផ្ទេរ ការដោះដូរ ការលក់ ការបញ្ចាំប្រទានកម្មជាដើម។ ហេតុនេះហើយនាំអោយម្ចាស់បំណុលមានការលំបាកក្នុងការអនុវត្តសិទ្ធិរបស់ខ្លួននៅពេលដែលម្ចាស់បំណុលឈ្នះក្ដី ដោយសារតែមើលឃើញបែបនេះហើយទើបបានជាក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦ មានគោលបំណងការពារសិទ្ធិ និង ផលប្រយោជន៍របស់ម្ចាស់បំណុលរហូតដល់នីតិវិធី បណ្ដឹងដល់ទីបញ្ចប់។ ហើយមិនថាម្ចាស់បំណុលនោះជាអ្នកណា មកពីណា ក៏ដោយ ឬ ទោះម្ចាស់ជាជនជាតិអ្វី ក៏ដោយអោយតែម្ចាស់មានសមត្ថភាពគ្រប់គ្រាន់ស្រប តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ទោះបីជាម្ចាស់បំណុលគ្មានសមត្ថភាពស្របតាមច្បាប់នៃប្រទេសរបស់

[5] មាត្រា៥៣០ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[6] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណី ,លេខ នស/រកម/១២០៧/០៣០ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ ២០០៧

ខ្លួនក៏ដោយ ក៏ម្ចាស់បំណុលអាចដាក់អោយតុលាការធ្វើការចាត់ចែងរក្សាការពារបានដែរ[7]។

ការចាត់ចែងរក្សាការពារនេះផងដែរបានចែកជា ការរឹបអូសជាណ្ដោះអាសន្ន និង ការចាត់ចែងជាបណ្ដោះអាសន្ន។ ការចាត់ចែងជាបណ្ដោះអាសន្នចែកជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន[8]។ ការរឹបអូសជាបណ្ដោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឲ្យសងជាប្រាក់។ចំណែកឯការចាត់ចែងជាបណ្ដោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិត្រូវបានរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទាអោយសងជាប្រាក់។ទោះជាយ៉ាងណាក៏ដោយបើនិយាយពីមុខងារ ការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានលក្ខណៈរួមត្រង់ថាមាន វិធានការទាំងពីរនេះគឺជាការចាត់ចែងដែលមានគោលបំណងរក្សាការពារនូវស្ថានភាពបច្ចុប្បន្ន សម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ដោយឡែកការចាត់ចែងជាបណ្ដោះអាសន្ន រហូតដល់ពេលកំណត់ទំនាក់ទំនងនៃសិទ្ធិជាស្ថាពរក្នុងគោលបំណងដកចេញ និង ទប់ស្កាត់នូវគ្រោះថ្នាក់ និង ការលំបាកនាពេលបច្ចុប្បន្ន ដែលបង្ករឡើងដោយភាពយឺតយ៉ាវនៃការកំណត់ទម្រង់នៃសិទ្ធិនោះជាស្ថាពរ។

## ២. វិសាលភាពនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារមានភាពធំទូលាយ ការអនុវត្តការចាត់ចែងរក្សាការពារធ្វើឡើងទៅបានលុះត្រាតែមានដីកាសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច។[9]ចំពោះការអនុវត្តបានគ្របដណ្ដប់លើការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្ន និងបានរួមបញ្ចូលផងដែរចំពោះបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។ វិសាលភាពនៃការអនុវត្តមានលក្ខណៈធំទូលាយ ផ្អែកលើគោលការណ៍ការពារនូវភាពស្របច្បាប់របស់ដើមបណ្ដឹង។

## ៣.មូលហេតុនៃការស្នើសុំរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងដើម្បីការពារសិទ្ធិ និង ប្រយោជន៍របស់ម្ចាស់បំណុល ក្នុងការប្រើសិទ្ធិទាមទារបំណុល ដោយយកលិខិតអនុវត្តពីតុលាការទៅ អនុវត្តដោយបង្ខំលើកូនបំណុលរបស់ខ្លួន។ ទោះបីជាការចាប់ផ្ដើមអនុវត្តដោយបង្ខំតម្រូវឱ្យបំពេញនូវ ល័ក្ខខ័ណ្ឌ ដូចជាអត្ថិភាពនៃលិខិតអនុវត្ត និង ការមកដល់នៃពេលកំណត់សងក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុនដោយមិនឱ្យមានការប្រែប្រួលផ្លូវ

[7] មាត្រា៣៤ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ០៦ កក្កដា ឆ្នាំ ២០០៦

[8] មាត្រា៥៣១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ឆ្នាំ ២០០៦

[9]មាត្រា ៥៤០ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ឆ្នាំ ២០០៦

ច្បាប់ និងស្ថានភាពជាក់ស្តែងក្នុងគោលដៅធានាដល់ការ អនុវត្តដោយបង្ខំនាពេលអនាគត។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ច ដូចជាសាលក្រមស្ថាពរជាដើម ហេតុនេះហើយដើម្បីឱ្យបានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ថែមទាំងត្រូវការពេលវេលាច្រើន។ ក៏ប៉ុន្តែមុនពេលទទួលសាលក្រមនេះ កូនបំណុលនៃការអនុវត្តអាច លក់ ឬ ផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនដែលជាហេតុមិនអាចធ្វើ ឬ ធ្វើឱ្យមានការលំបាក ដល់ធ្វើការអនុវត្តដោយបង្ខំ នៅពេលក្រោយបាន ឬ មួយក៏ភាគីណាមួយអាចទទទួលការខូចខាតធ្ងន់ធ្ងរ ឬទទួលគ្រោះថ្នាក់ដល់ឋានៈ របស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិរវាងភាគីទាំងសងខាង។ ក្នុងករណីនេះបុគ្គល ដែលចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារឱ្យមានការចាត់ចែងរក្សាការពារបាន។

## ផ្នែកទី២៖ ប្រភេទនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី

ប្រភេទនៃការចាត់ចែងរក្សាការពារ អាចត្រូវបានដាក់ឲ្យអនុវត្តបានជាច្រើនសណ្ឋានទៅតាមកាលៈទេសៈនៃសំណុំរឿង។ ដែលមានគោលបំណងជៀសវាងផលលំបាក និងភាពមិនអាចអនុវត្តបាននូវ នីតិវិធីអនុវត្តដោយបង្ខំនាពេលអនាគត។ ដែលក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវខ្លឹមសារខាងក្រោម ដែលអាចធ្វើការចាត់ចែងរក្សាការពារបាន[10]៖

### ១. ការរឹបអូសបណ្តោះអាសន្ន

ការរឹបអូសបណ្តោះអាសន្ន ជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់។[11]

ការរឹបអូសបណ្តោះអាសន្ន មានគោលបំណងដើម្បីទប់ស្កាត់ដល់កូនបំណុលក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន និង ធានាបាននូវទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគត។ ក្នុងសំណុំរឿងរដ្ឋប្បវេណី កម្មវត្ថុនៃការរឹបអូសបណ្តោះអាសន្នត្រូវបានគេបែងចែកជាច្រើនប្រភេទ ក្នុងនោះរួមមាន ចលនវត្ថុ[12] សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[13] អចលនវត្ថុ[14] នាវា[15]។

- ចលនវត្ថុ៖ ការរឹបអូសជាបណ្តោះអាសន្ននៃចលនវត្ថុ ត្រូវធ្វើតាមការអនុវត្តដោយអាជ្ញាសាលា ដែលដូច

[10] មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[11] កថាខណ្ឌទី១ មាត្រា ៥៣១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[12] មាត្រា ៥៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[13] មាត្រា ៥៦៦ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[14] មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[15] មាត្រា ៥៦៨ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

គ្នាទៅនឹងការរឹបអូសអចលនវត្ថុដែរ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាសាច់ប្រាក់ អាជ្ញាសាលាមិនត្រូវបញ្ជូនទៅម្ចាស់បំណុលផ្ទាល់ទេ ត្រូវបញ្ជូនទៅតុលាការ[16] ។ អាជ្ញាសាលាដែលធ្វើការរឹបអូសនូវចលនវត្ថុដែលបានចុះបញ្ជី ដូចជា រថយន្ត ទោចក្រយានយន្ត ត្រូវផ្ទុកផ្ដាក់ឱ្យសរសេរនូវរបាយការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជី ហើយការរឹបអូសនោះនឹងមានអានុភាព។

- អចលនវត្ថុ៖ សំដៅទៅលើ អគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអគារនោះ សិទ្ធិជួលអចិន្ត្រៃ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។[17] ការរឹបអូសជាបណ្ដោះអាសន្ននៃអចលនវត្ថុ ត្រូវធ្វើឡើងដោយអាជ្ញាសាលា។ការរឹបអូសបណ្ដោះអាសន្នចំពោះអចលនវត្ថុ មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ដែលជាត្រូវការពារ។
- សិទ្ធិលើបំណុល៖ ការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ត្រូវធ្វើឡើងដោយតុលាការអនុវត្តរក្សាការពារ។ ក្នុងករណីដែលកូនបំណុលទី ៣ ដែលបានទទួលការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល បានផ្ញើរសិទ្ធិលើបំណុលនោះ ឬមួយផ្នែកនៃចំនួនប្រាក់ដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន ក្នុងចំណោមប្រាក់ផ្ញើរនោះ ត្រូវចាត់ទុកថាជាការផ្ញើរប្រាក់រំដោះ តែចំពោះភាគដែលលើសចំនួនទឹកប្រាក់ដែលស្មើនឹងរំដោះពីការរឹបអូសជាបណ្ដោះអាសន្ននោះ ការផ្ញើរនៅតុលាការបង្កើតឱ្យមានអានុភាពនៃការទូទាត់ទៅកូនបំណុលនៃការអនុវត្ត។[18]
- នាវា៖នាវាសំដៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០ តោន ទោះជាមិនបានចុះបញ្ជី ឬបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក្តី[19]។ ការរឹបអូសបណ្ដោះអាសន្នចំពោះនាវា គឺអាជ្ញាសាលាធ្វើការដកហូតលិខិតបញ្ជាក់សញ្ជាតិនាវានោះ។មិនខុសគ្នាពីការរឹបអូសជាបណ្ដោះអាសន្ននៃអចលនវត្ថុ និងចលនវត្ថុប៉ុន្មានដែរត្រង់ចំណុចផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស។ការរឹបអូសបណ្ដោះអាសន្នចំពោះនាវា ត្រូវអនុវត្តដោយតុលាការអនុវត្តរក្សាការពារ។

## ២. ការចាត់ចែងរក្សាការពារបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាការចាត់ចែងដែលរក្សាទុកនូវស្ថាន

[16] កថាខណ្ឌទី ២ មាត្រា ៥៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[17] កថាខណ្ឌទី១ មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[18] ទំព័រទី ៥៥៥ និង៥៥៦ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[19] មាត្រា ៥៥៤ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

ភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថាម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការកែប្រែស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។[20]

**ក. ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរកាន់កាប់**

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរកាន់កាប់ មានគោលបំណងហាមឃាត់កូនបំណុលក្នុងការផ្ទេរនូវការកាន់កាប់វត្ថុដែលបានកំណត់ជាក់លាក់ទៅឱ្យតតិយជន ហើយកំណត់អំពីភាគីម្ខាងទៀតនៃការទាមទារឱ្យប្រគល់។ ការចាត់ចែងជាបណ្តោះអាសន្នក្នុងការទប់ស្កាត់ការផ្ទេរការកាន់កាប់នេះ បានរក្សាការពារលើសិទ្ធទាមទារប្រគល់វត្ថុដែលបានកំណត់ជាក់លាក់។

**ខ.ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង**

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងមានគោលបំណងហាមឃាត់កូនបំណុលកុំឱ្យមានការចាត់ចែង ធ្វើការផ្ទេរកម្មសិទ្ធិ ដាក់បន្ទុក ដកបន្ទុក លើវត្ថុដែលបានកំណត់ជាក់លាក់ ហើយកំណត់ភាគីម្ខាងទៀតនៃការទាមទារ។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង បានរក្សាការពារនូវសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកចំពោះកម្មវត្ថុដែលបានកំណត់ជាក់លាក់។ ជាក់ស្តែង គេឃើញមានស្ទើរគ្រប់ករណី ជាសិទ្ធិក្នុងការទាមទារឱ្យចុះបញ្ជី។

**៣ .ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន**

ការចាត់ចែងរក្សាការពារចំពោះការកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន ជាយន្តការម្យ៉ាងដែលបានធានាដល់ការបាត់បង់ និងខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតមានឡើងចំពោះម្ចាស់បំណុល។[21] ជាយន្តការដែលកំណត់នូវឋានៈជាបណ្តោះអាសន្ននៃបុគ្គល ឬភាគី ដើម្បីកំណត់នូវសិទ្ធិជាបណ្តោះអាសន្នរបស់អ្នកដាក់ពាក្យសុំក្នុងការបន្តនីតិវិធីបណ្តឹងអង្គសេចក្តី និងមានភាពចាំបាច់សម្រាប់កំណត់សិទ្ធិជាបណ្តោះអាសន្ន នៃសិទ្ធិបុគ្គលណាមួយដែលបានដាក់ពាក្យសុំ។

ការកំណត់ឋានៈបុគ្គលពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ ជាឋានៈរូបវន្តបុគ្គល នីតិបុគ្គលដែលតុលាការបានចេញដីកាសម្រេចរក្សាការពារ ដែលបានកំណត់ថាបុគ្គលនោះមានសិទ្ធិ ក៏ដូចជាកាតព្វកិច្ចបែបណាក្នុងការអនុវត្តជាបណ្តោះអាសន្ន។ ករណីមានបណ្តឹងកំពុងបន្តដំណើរការនីតិវិធី វាមានការលំបាកក្នុងការ

[20] កថាខណ្ឌទី ២ មាត្រា ៥៣១ ចំណុច ខ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[21] មាត្រា ៥៤៨ កថាខ័ណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

កំណត់នូវអត្ថិភាព និងនត្ថិភាពនៃគូភាគី ដែលចាំបាច់កំណត់នូវឋានៈបុគ្គលនោះជាបណ្ដោះអាសន្ន ដើម្បីធានាដល់ស្ថេរភាព និងនិរន្តរភាពនៃដំណើរការនីតិវិធីទាំងមូល។ ជាពិសេស ការចាត់ចែងរក្សាការពារក្នុងការកំណត់ឋានៈបុគ្គលជាបណ្ដោះអាសន្ន មានលក្ខណៈខុសគ្នាពីការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយមិនមែនមានគោលបំណងធ្វើការរក្សាការពារសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគតនោះទេ។

## ផ្នែកទី៣៖ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ

### ១. លក្ខណៈបណ្ដោះអាសន្ន

នៅក្នុងបណ្ដឹងអង្គសេចក្ដី ដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្ដីសម្រេច ដោយសាលក្រម ឬសាលដីកាឡើយ។ ដីកាសម្រេចរក្សាការពារ គឺជានីតិវិធីមួយដែលមានលក្ខណៈបណ្ដោះអាសន្នប៉ុណ្ណោះ។ សិទ្ធិលើបំណុល ឬសិទ្ធិទាមទារផ្សេងៗទៀតនៃបណ្ដឹងអង្គសេចក្ដីមិនត្រូវបានបញ្ជាក់ទេថា មានអត្ថិភាព និងនត្ថិភាពឡើយ។

### ២ .លក្ខណៈបន្ទាន់បង្ខំ

លក្ខណៈបន្ទាន់នៃដីកាសម្រេចរក្សាការពារ ធ្វើឡើងដើម្បីការពារផលប្រយោជន៍ស្របច្បាប់ និងបង្ការកុំឱ្យមានការខូចខាតនូវកម្មវត្ថុនៃវិវាទជាដើម។ ហេតុនេះនីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារ មានលក្ខណៈបន្ទាន់ និងប្រញាប់។ ដើម្បីបំពេញនូវលក្ខណៈបន្ទាន់បង្ខំនេះ ចៅក្រមអាចប្រើប្រាស់នីតិវិធីណាមួយក៏បានក្នុងចំណោមការទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរភាគីនៃបណ្ដឹងតែម្ដង ដែលជាឆន្ទានុសិទ្ធិសម្រេចរបស់លោកចៅក្រមដែលគិតថា ជានីតិវិធីដែលមិនប្រើប្រាស់ពេលវេលាយូរ។

### ៣. លក្ខណៈបន្ទាប់បន្សំ

នីតិវិធីចាត់ចែងរក្សាការពារ អាចប្រើប្រាស់ជំនួសនីតិវិធីអនុវត្តដោយបង្ខំបានក្នុងការធានាដល់សិទ្ធិរបស់ម្ចាស់បំណុល។ ដូចដែលបានរៀបរាប់ក្នុងចំណុចនៃលក្ខណៈបណ្ដោះអាសន្ននៃដីកាសម្រេចចាត់ចែងរក្សាការពារ ជានីតិវិធីមួយដែលបង្កើតឡើងជាបណ្ដោះអាសន្ន ដូចច្នេះវាពុំមានឥទ្ធិពលទៅលើ បណ្ដឹងអង្គសេចក្ដីទេ ហើយការកំណត់សមត្ថកិច្ចរបស់តុលាការវាផ្អែកលើបណ្ដឹងអង្គសេចក្ដីប៉ុណ្ណោះ ហេតុដូចនេះ នីតិវិធីចាត់ចែងរក្សាការពារជាលក្ខណៈបន្ទាប់បន្សំនៃនីតិវិធីបណ្ដឹង។

### ៤ . លក្ខណៈសម្ងាត់

ដើម្បីបង្ការក្នុងការចាត់ចែងទ្រព្យសម្បត្តិ របស់កូនបំណុល ក្នុងករណីម្ចាស់បំណុលដាក់ពាក្យសុំរក្សាការពារលើចលនវត្ថុ ឬអចលនវត្ថុទាំងនោះ នីតិវិធីនៃការចាត់ចែងរក្សាការពារត្រូវតែរក្សាការសម្ងាត់ជូនម្ចាស់

បំណុល។ ម្យ៉ាងវិញទៀតពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារពុំចាំបាច់មានការបញ្ជូនទៅកូនបំណុលឡើយ។ ខុសពីនីតិវិធីនៃបណ្តឹងអង្គសេចក្តី ដែលតម្រូវឱ្យមានការបញ្ជូនដីកានានាដល់កូនបំណុលដើម្បីទទួល និងដឹងអំពីពត៌មានផ្សេងៗ នេះសបញ្ជាក់ឱ្យឃើញផងដែលអំពីលក្ខណៈសម្ងាត់របស់ដីកាសម្រេចរក្សាការពារ។

## ផ្នែកទី៤៖ ដែនសមត្ថកិច្ចនៃនីតិវិធីចាត់ចែងរក្សាការពារ ដែនសមត្ថកិច្ចតុលាការ

នីតិវិធីនៃការចាត់ចែងរក្សាការពារ មានចរិតលក្ខណៈជានីតិវិធីដែលបំពេញបន្ថែមលើការអនុវត្តដោយបង្ខំ ដូចនេះរឿងក្តីនៃនីតិវិធីចាត់ចែងរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការចាត់ចែងនោះស្ថិតនៅ។[22] មិនតែប៉ុណ្ណោះ បណ្តឹងរដ្ឋប្បវេណី ភាគីគឺជាម្ចាស់បណ្តឹងផ្ទាល់ ដូចនេះការកំណត់ដែនសមត្ថកិច្ចតុលាការជារឿងសំខាន់ ដោយហេតុថានៅពេលដាក់ពាក្យសុំទៅតុលាការ កាលណាពាក្យសុំខុសពីសមត្ថកិច្ចរបស់ តុលាការ នោះពាក្យសុំនោះនឹងត្រូវបានលើកចោលដោយតុលាការនោះ។ នៅក្នុងនីតិវិធីនៃការចាត់ចែងបណ្តឹងរដ្ឋប្បវេណីមានគោលបំណងសុំឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិ របស់បុគ្គលឯកជន។ ស្ថាប័នមានសមត្ថកិច្ចលើការចាត់ចែងរក្សាការពាររួមមាន៖ **អាជ្ញាសាលា សាលាដំបូងរាជធានី/ខេត្ត សាលាឧទ្ធរណ៍ តុលាការកំពូល តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី សាលាដំបូងរាជធានី/ខេត្ត ដែលមានសមត្ថកិច្ចលើវត្ថុនៃកម្មវត្ថុ។**

**អាជ្ញាសាលា** គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយ ដែលទទួលបន្ទុកក្នុងការអនុវត្តដោយ បង្ខំ និងការងារពាក់ព័ន្ធ ហើយដោយមានមន្ត្រីរាជការដែលមានឈ្មោះថា "អាជ្ញាសាលា"។ អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយស្ថិតនៅក្រោមក្រសួងយុត្តិធម៌ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការ[23]។ អាជ្ញាសាលា មិនមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការ អនុវត្តទេ ។ ច្បាប់អនុញ្ញាតឱ្យតុលាការ អនុវត្តផ្តល់ការណែនាំប្រគល់សិទ្ធិ និង បង្គាប់អាជ្ញាសាលានៅ ក្នុងករណីជាក់លាក់ ដូចជា(ការអនុវត្តថ្ងៃសម្រាក ឬ ពេលយប់) ដោយអាជ្ញាសាលា ត្រូវបង្ហាញលិខិត បញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតពីសាលាដំបូង ដែលខ្លួនស្ថិតនៅ ឬ តុលាការ អនុវត្តស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញសេចក្តីបង្គាប់[24]។ ដោយបញ្ញត្តិទាំងនេះត្រូវបានរៀបចំឡើង ដោយយក ទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរមកជាមូលដ្ឋាន ដោយគិតពិចារណាអំពីចរិត លក្ខណៈរបស់ ស្ថាប័ននីមួយៗផងដែរ។ ចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យ ពីសាលា ដំបូងដែលខ្លួនស្ថិតនៅចំពោះមុខងាររបស់ខ្លួន។

[22] មាត្រា ៥៤០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[23] មាត្រា ២៤៦ កថាខណ្ឌទី ៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[24] មាត្រា ៣៤០ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

នីតិវិធីនៃការអនុវត្តដោយបង្ខំដែលអាជ្ញាសាលាទទួលបន្ទុកដោយឯករាជ្យក្នុងនាមជាស្ថាប័នអនុវត្តរួមមាន៖

- ❖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ
- ❖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ
- ❖ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ❖ ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ។

ក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំនុចដូចជាការថែរក្សា គ្រប់គ្រងអចលនវត្ថុ ដែលជាកម្មវត្ថុក្នុងការអនុវត្តការលក់ ការដកហូតលិខិតបញ្ជាក់សញ្ជាតិនាវាជា ដើម។

**សាលាដំបូងរាជធានី/ខេត្ត៖** តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការ ដែលអាចទទួលពាក្យបណ្តឹងដោយស្របច្បាប់ និងវិនិច្ឆ័យរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន[25]។ តុលាការដែលត្រូវអនុវត្ត ការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តការចាត់ចែងរក្សាការពារ[26] ហើយសមត្ថកិច្ចនេះអាចកំណត់បានទៅលើ លំនៅដ្ឋានរបស់ចុងចម្លើយ ឬ កំណត់ទៅតាមទ្រព្យសម្បត្តិដែលតាំងនៅ។ ក្នុងករណីដែលបណ្តឹងអង្គសេចក្តីកំពុងចាត់ការនៅតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ អាចមានករណីដែលសាលាឧទ្ធរណ៍អនុវត្តការចាត់ចែងរក្សាការពារ ។ សាលាដំបូង រាជធានី ខេត្ត គឺជាអាជ្ញាធរដែលមានសមត្ថកិច្ចរបស់សាលាក្តីដែលមានតួនាទី ទទួលជំនុំជម្រះរឿងវិវាទ ដែលគូភាគីប្តឹង ឬ ក៏សមត្ថកិច្ចសាលាណាមួយដែលមានតួនាទីកាត់ក្តី ហើយសាលក្រមរបស់សាលានោះត្រូវច្បាប់ឱ្យអនុវត្ត។ សាលាជម្រះក្តីដែលទទួលពាក្យបណ្តឹងខុសពីសមត្ថកិច្ចរបស់ខ្លួន ត្រូវតែ ប្រកាសថាខ្លួនគ្មានសមត្ថភាព ហើយប្រាប់គូភាគី ឱ្យទៅរកសាលាដែលមានសមត្ថភាពក្នុងរឿងវិវាទរបស់គូភាគីនោះ។ ប្រភេទនៃនីតិវិធីអនុវត្តដែលស្ថិតនៅក្រោមសមត្ថកិច្ចតុលាការនេះរួមមាន៖

- ❖ ការអនុវត្តដោយបង្ខំ
- ❖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធលើបំណុល និងទ្រព្យសម្បត្តិផ្សេងៗទៀត លើអចលនវត្ថុ
- ❖ ការអនុវត្តដោយបង្ខំអោយប្រគល់វត្ថុក្នុងករណីដែលវត្ថុត្រូវបានកាន់កាប់ដោយ តតិយជន
- ❖ ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច ដែលមានគោលបំណងឱ្យធ្វើ ឬមិនធ្វើសកម្មភាពជាដើម។

**សាលាឧទ្ធរណ៍៖** តុលាការឧទ្ធរណ៍ ក៏ជាតុលាការដែលមានដែនសមត្ថកិច្ចក្នុងការចាត់ចែងរក្សាការពារបានដែរ ក្នុងករណីដែលបណ្តឹងអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍។

[25] មាត្រា ៧ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[26] កថាខណ្ឌទី ៣ មាត្រា ៥៣២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

ឧទាហរណ៍៖ ម្ចាស់បំណុលស្ថិតនៅដំណាក់កាលដំបូង នៅសាលាដំបូងមិនបានធ្វើការដាក់ពាក្យប្តឹងអំពីវត្ថុដែលខ្លួនទាមទារ ហើយពេលនីតិវិធីដំណើរការដល់សាលាឧទ្ធរណ៍ ម្ចាស់បំណុលនោះមានចំណុចវិវាទថ្មី ប្តឹងសុំឱ្យតុលាការឧទ្ធរណ៍សម្រេចសេចក្តីនោះ ។ តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តីខាងលើនេះ គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។

# ជំពូកទី២
# យន្តការនៃការចាត់ចែងរក្សាការពារ

គោលបំណងដែងចង់រក្សានូវស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចតុលាការ ដើម្បីរក្សាការពារសិទ្ធិរបស់បុគ្គលណាម្នាក់នៅពេលដែលមានការព្រួយបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចកើតមាន ឬមិនអាចអនុវត្ត

ទៅបានដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃកម្មវត្ថុ នោះគេអាចធ្វើការសុំរក្សាការពារបាន។ មួយវិញទៀត ការចាត់ចែងរក្សាការពារ ជានីតិវិធីម្យ៉ាងដែលមានលក្ខណៈបណ្ដោះអាសន្នក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលនៅពេលដែលអនុវត្តដោយបង្ខំ ឬមិនអាចធ្វើការសម្រេចអំពីសិទ្ធិបានដោយសារការប្រែប្រួលស្ថានភាពនៃទ្រព្យសម្បត្តិរបស់កូនបំណុល លើសពីនេះ ក្នុងករណីដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ណាមួយបន្ទាន់កើតមានដល់ឋានៈរបស់ភាគី ដោយសារតែវិវាទនៃសិទ្ធិ នោះការចាត់ចែងរក្សាការពារនឹងអាចកើតមានឡើង។

## ផ្នែកទី១ នីតិវិធីក្នុងការសុំចេញដីកាសម្រេចចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះការធានាក្នុងការអនុវត្តដោយបង្ខំនាពេលអនាគតរបស់កូនបំណុល។ហេតុនេះហើយ ក្នុងនាមយើងចង់អោយតុលាការចេញដីកាចាត់ចែងរក្សាការពារ ត្រូវធ្វើដូចម្ដេចខ្លះ?

គោលការណ៍ក្នុងរឿងរដ្ឋប្បវេណី ភាគីត្រូវបានដាក់ពាក្យសុំ ទើបតុលាការសម្រេចដោយឆន្ទានុសិទ្ធិ ហើយក្នុងការអនុវត្តនេះផងដែរលុះត្រាតែមានការបញ្ជូន ទៅភាគីឱ្យបានដឹងជាមុន។

### ១. ការសុំដីកាសម្រេចចាត់ចែងរក្សាការពារ

ដីកាសម្រេចការពារត្រូវមានជាចាំបាច់នូវចំណុចសំខាន់ៗ ដើម្បីបញ្ជាក់រឿងក្ដីរួមមាន ៖ សញ្ញាណនៃសិទ្ធិលើបំណុលដែលទាមទារ និងលេខសំណុំរឿង។ ដោយសារតែដីកាសម្រេចរក្សាការពារត្រូវបានចេញដោយផ្អែកលើពាក្យសុំ ដូច្នេះដីកាសម្រេចនេះ ត្រូវតែជាដីកាដែលទាក់ទងនឹងសំណុំរឿងជាក់លាក់ណាមួយដែលពាក្យសុំត្រូវបានដាក់។ ម្យ៉ាងវិញទៀតយើងមិនអាចបញ្ជាក់អំពីសំណុំរឿងបានឡើយ បើដីកាសម្រេចនោះមិនបានសរសេរអំពីចំណុចសំខាន់ៗតាមទម្រង់ដើម្បីបញ្ជាក់នូវសំណុំរឿងនោះទេ[27]។

#### ក. អត្តសញ្ញាណ និង អាសយដ្ឋាននៃគូភាគី

ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

នៅក្នុងពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរអោយបានច្បាស់លាស់ថា នរណាជាអ្នកប្ដឹង? តើអ្នកនោះមានអាសយដ្ឋាននៅទីណា? មិនតែប៉ុណ្ណោះពាក់ព័ន្ធប្រសិទ្ធភាពនៃការទាក់ទងដែលសម

[27] មាត្រា៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

ស្របទៅនឹងការជឿនលឿនរបស់សង្គមនាពេលបច្ចុប្បន្ន គឺ លេខទូរស័ព្ទដែលគួរតែត្រូវបានសរសេរភ្ជាប់មកជាមួយ ពីព្រោះនាំអោយមានភាពងាយស្រួលក្នុងការជូនដំណឹង។

**ខ. អត្ថន័យនៃនៃការសម្រេចដែលសុំអោយតុលាការចេញ**

ដោយហេតុថា ការចាត់ចែងរក្សាការពារមានរហូតដល់ទៅ៣ប្រភេទ។ ដូច្នេះ ខ្លឹមសារនៃដីកាសម្រេចការពារ គឺជាការសំខាន់ដែលពុំអាចធ្វេសប្រហែសបាន លើសពីនេះទៅទៀតខ្លឹមសារនៃដីកាសម្រេចរក្សាការពារត្រូវមានភាពច្បាស់លាស់ ដើម្បីបញ្ជាក់ពីប្រភេទនៃដីកាសម្រេចរក្សាការពារមួយអាចជា៖

- ❖ ដីកាសម្រេចការពារ ដោយធ្វើការរឹបអូសជាបណ្តោះអាសន្ន[28]
- ❖ ដីកាសម្រេចរក្សាការពារ ដោយធ្វើការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ
- ❖ ដីកាសម្រេចរក្សាការពារដោយធ្វើការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

**គ. ទំនាក់ទំនងគតិយុត្តនៃការដាក់រក្សាការពារ**

ត្រង់ចំណុចនេះត្រូវសរសេរពីអង្គហេតុដែលត្រូវទាមទារ និងអង្គហេតុសំខាន់ៗផ្សេងទៀតបើមានពីព្រោះថា ការសរសេរអំពីអង្គហេតុទាំងពីរនេះ គឺ ដើម្បីបង្កើតសិទ្ធិក្នុងការស្នើសុំកិច្ចរក្សាការពារ។ជាការពិតអង្គហេតុដែលជាមូលហេតុនៃការទាមទារគឺត្រូវសរសេរនៅក្នុងបណ្តឹងឯណោះ ប៉ុន្តែដីការក្សាការពារអាចចេញមុនពាក្យបណ្តឹងអង្គសេចក្តី ត្រង់នេះមានន័យថាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវសរសេរយ៉ាងណាអោយអត្ថន័យ និង ខ្លឹមសារដូចអង្គហេតុដែលជាមូលហេតុនៃការទាមទារដែរ។

**ឃ. ភាពចាំបាច់នៃការដាក់រក្សាការពារ**

នៅក្នុងពាក្យសុំដីការសម្រេចរក្សាការពារភាគីសុំត្រូវសរសេរបញ្ជាក់អោយបានច្បាស់លាស់អំពីតម្រូវការចាំបាច់ ដើម្បីអោយចៅក្រមចេញសេចក្តីសម្រេចរក្សាការពារ។ជាពិសេសពត៌មាន ភាគីដែលជាម្ចាស់បំណុលមានការទាក់ទិននិងស្ថានភាពក្នុងហានិភ័យទ្រព្យសម្បត្តិរបស់កូនបំណុល។ ដូច្នេះពាក់ព័ន្ធនិងចំណុចពិសេសដែលត្រូវសរសេរ នៅក្នុងពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ គប្បីសរសេរយ៉ាងណាបង្ហាញអោយឃើញពីភាពចាំបាច់ ដើម្បីអោយចៅក្រមអាចជឿជាក់បានថា បើមិនមានវិធានការសម្រេចរក្សាការពារទេនោះ ការអនុវត្តដោយបង្ខំនៅពេលអនាគតអាចនឹងជួបផលវិបាកជាខ្លាំង។

**ង. ភស្តុតាងបញ្ជាក់**

នៅក្នុងពាក្យសុំ ម្ចាស់បំណុលគួរគប្បីសរសេរអោយបានច្បាស់លាស់ និងសរសេរនូវភស្តុតាង(ឯកសារ

អំពីសេចក្តីបញ្ជាក់ដំបូង) ដែលបញ្ជាក់នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនិងត្រូវបាននៃការរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ ពីព្រោះការយោងនេះមានប្រយោជន៍ចំពោះតុលាការ ក្នុងការស្វែងរកទំនាក់ទំនង រវាងអង្គហេតុ និង ភស្តុតាង ។

ចំពោះការពិពណ៌នាគឺផ្តោតសំខាន់ទៅលើឯកសារដែលភ្ជាប់មកជាមួយពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារអាចជា បញ្ជីភាគី បញ្ជីសិទ្ធិលើបំណុល បញ្ជីសារពើភ័ណ្ឌញ្ជីសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ។ តាមពិតទៅប្រភេទបញ្ជីពិពណ៌នាទាំងបីនេះ គឺ មិនត្រូវជាមួយពាក្យសុំទេ ប៉ុន្តែវាជាផ្នែកមួយនៃពាក្យសុំ។ បញ្ជីសារពើភ័ណ្ឌទាំងនេះមានតួនាទីមួយផ្សេងទៀត គឺ ផ្តល់ភាពងាយស្រួលដល់ចៅក្រមដែលចេញដីកាសម្រេចរក្សាការពារ ដោយពុំចាំបាច់សរសេរខ្លឹមសារនៃឯកសារដែលភ្ជាប់មកនោះ នៅលើដីការរក្សាការពារនោះទៀតទេ ដោយហេតុថាចៅក្រមគ្រាន់តែឆ្លើយតបដោយចេញដីការសម្រេចរក្សាការពារលើលិខិតមួយយ៉ាងខ្លី តែត្រូវភ្ជាប់មកវិញនូវឯកសារដែលម្ចាស់បំណុលបានភ្ជាប់មក។

## ២ . ដែនសមត្ថកិច្ច

### ក.តុលាការដែលមានសមត្ថកិច្ចចំពោះការរឹបអូសជាបណ្តោះអាសន្ន

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ គឺជាតុលាការដែលមានសមត្ថកិច្ចចំពោះការរឹបអូសជាបណ្តោះអាសន្ន ។ សមត្ថកិច្ចនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ[29]។ នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុ នោះត្រូវបញ្ជាក់ពីអត្តសញ្ញាណនៃវត្ថុដែលជាកម្មវត្ថុនោះ ហើយបើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាអចលនវត្ថុវិញ ត្រូវបញ្ជាក់ពីទីកន្លែងដែលអចលនវត្ថុនោះស្ថិតនៅ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថា (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍)[30]។

### ខ.តុលាការដែលមានសមត្ថកិច្ចចំពោះការចាត់ចែងជាបណ្តោះអាសន្ន

ក្នុងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្រៅពីតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ ក៏ជាតុលាការដែលមានសមត្ថកិច្ចដែរ[31]។ ផ្ទុយទៅវិញ មានតែតុលាការនៃបណ្តឹងអង្គសេចក្តីទេ ដែលមានសមត្ថកិច្ច

[29] មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

[30] មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

[31] មាត្រា ៥៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

ផ្តាច់មុខលើការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[32]។

**គ.ការបង់ពន្ធ**

ពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ ត្រូវដាក់ចូលទៅការិយាល័យរដ្ឋបាលនៃលេខាធិការដ្ឋានរបស់តុលាការដែលមានសមត្ថកិច្ច។នៅពេលដាក់ពាក្យសុំឲចេញដីកាសម្រេចរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០ (ប្រាំពាន់រៀល)ទៅតុលាការ[33]។

**ឃ.សេចក្តីវិនិច្ឆ័យរបស់តុលាការ**

នៅពេលពាក្យសុំត្រូវបានដាក់ទៅតុលាកាពិនិត្យអំពី នត្ថិភាព ឬ អត្ថិភាព នៃសមត្ថកិច្ចព្រមទាំងភាពត្រឹមត្រូវនៃពាក្យសុំ។បើតុលាការយល់ឃើញថា មិនមានសមត្ថកិច្ចលើសំណុំរឿងរក្សាការពារទេ តុលាការត្រូវផ្ទេរសំណុំរឿងនោះទៅតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន[34]។ បន្ទាប់ពីការពិនិត្យលើសមត្ថកិច្ចហើយ ចៅក្រមចាប់ផ្តើមពិនិត្យពាក្យសុំដីការរក្សាការពារវិញម្តង គឺ ពិនិត្យទៅលើចំណុចនីមួយៗដែលត្រូវសរសេរនៅក្នុងពាក្យសុំនោះថាត្រឹមត្រូវតាមច្បាប់កំណត់ដែរឬទេ[35]។

ក្នុងករណីពាក្យសុំផ្ទុយនិងលក្ខខណ្ឌខាងលើ តុលាការត្រូវបង្គាប់អោយកែតម្រូវចំណុចខ្វះខាតចំពោះពាក្យសុំនោះ ហើយប្រសិនបើអ្នកដាក់ពាក្យសុំមិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការត្រូវលើកពាក្យសុំនោះចោលដោយដីកាសម្រេច[36]។

**៣ . កម្មវត្ថុនៃការវិនិច្ឆ័យ**

នៅពេលដែលពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារបានដាក់បញ្ជូនដល់តុលាការ តុលាការមុននឹងចេញដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់ម្ចាស់បំណុល ឬ លើកពាក្យសុំនោះចោលបាន តុលាការធ្វើការវិនិច្ឆ័យទៅលើចំណុចដូចជាៈ

ក. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ជាសិទ្ធិលើបំណុលដែលមានគោលបំណងឲសងជាប្រាក់។

ខ. ភាពជាចាំបាច់នៃការរក្សាការពារ ជាករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនិងមិនអាចធ្វើបាន ឬ និងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តដោយបង្ខំ។

គ. អចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន ដី អាគារដែលត្រូវបានចុះបញ្ជីចំណែកនៃ

[32] មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

[33] មាត្រា ៥៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

[34] មាត្រា ៥៣៩ និងមាត្រា ១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ ៦កក្កដា ឆ្នាំ ២០០៦

[35] មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

[36] មាត្រា ៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

កម្មសិទ្ធិអវិភាគ ដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។ក្រៅពីនេះក៏អាចរឹបអូសជាបណ្តោះអាសន្នបានដែរបើកូនបំណុលគឺជា៖

- ភោគីអចលនវត្ថុដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីតែមិនចុះបញ្ជីអចលនាទ្រព្យ។
- ភោគីដែលកាន់កាប់អចលវត្ថុតាំងពីពេលប្រកាសអោយប្រើច្បាប់ភូមិបាលឆ្នាំ២០០១ ដែលធ្វេសប្រហែសមិនបានចុះបញ្ជីភោគៈ។

## ៤.វិធីនៃការវិនិច្ឆ័យ

ក.ការធ្វើសេចក្តីបញ្ជាក់ដំបូង ជាជម្រើសទី១ សម្រាប់តុលាការក្នុងវិនិច្ឆ័យលើពាក្យសុំៗវិធីនេះគឺតុលាការធ្វើការពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង និងការសាកសួរម្ចាស់បំណុល ឬ សាក្សីដែលមានវត្តមានភ្លាមបាន។នៅក្នុងការអនុវត្តជាក់ស្តែងការធ្វើសេចក្តីបញ្ជាក់ដំបូងនេះ គឺចៅក្រមធ្វើបានត្រឹមតែពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ឬ អាចសួរម្ចាស់បំណុលខ្លះៗតែប៉ុណ្ណោះ។

ខ. កាលបរិច្ឆេទនៃការសាកសួរ ជាជម្រើសទី២ ករណីដែលសេចក្តីបញ្ជាក់ដំបូងមិនទាន់រឹងមាំ តុលាការកំណត់កាលបរិច្ឆេទដែលគូភាគីអាចចូលរួមបានដើម្បីធ្វើការសួរ។នៅក្នុងការអនុវត្តជាក់ស្តែង ការសួរនេះបែរជាធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទៅវិញ។ចំណុចនេះ នៅមិនទាន់មានភាពច្បាស់លាស់ថា គប្បីត្រូវធ្វើដូចម្តេចនៅឡើយទេពីព្រោះច្បាប់ពុំបានចែងហេតុនេះត្រូវស្ថិតនៅក្នុងរង្វង់នៃការបកស្រាយ។

គ. នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ គឺ ជាទម្រង់មួយនៃការជម្រះក្តី ដែលក្នុងនោះសកម្មភាពរបស់តុលាការ និងសកម្មភាពរបស់ភាគី។ ចំពោះការជម្រះក្តីនោះត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្តាប់សេចក្តីថ្លែងការណ៍នោះ នៅសាលសវនាការជាសាធារណៈនៅកាលបរិច្ឆេទដែលភាគីអាចចូលរួមបាន។ប៉ុន្តែនីតិវិធីនេះធ្វើអោយប៉ះពាល់ដល់ចារិកលក្ខណៈនៃដីកាសម្រេចរក្សាការពារ។

## ផ្នែកទី២៖ ប្រភេទនៃការចេញដីកាសម្រេចរក្សាការពារ

## ១. ដីការឹបអូសបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសបណ្តោះអាសន្នជាដីកាសម្រេចដែលមានគោលបំណងឱ្យសងជាប្រាក់។

ដីកាសម្រេចរឹបអូស ជាបណ្តោះអាសន្នត្រូវចេញនៅពេលដែលមានលក្ខខណ្ឌទាមទារសម្រេចរឹបអូសជាបណ្តោះអាសន្ន និងមានលក្ខខណ្ឌចាំបាច់ សម្រាប់ការធ្វើបណ្តឹងត្រូវបានបំពេញសព្វគ្រប់។ ជាគោលការណ៍តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយកំណត់កម្មវត្ថុជាក់លាក់ លើកលែងតែដីកា

សម្រេចរឹបអូសចលនវត្ថុជាបណ្ដោះអាសន្ន ប៉ុណ្ណោះមិនចាំបាច់កំណត់កម្មវត្ថុជាក់លាក់ណាមួយទេ។[37]

ចំពោះដីកាសម្រេចប្រភេទនេះ តុលាការត្រូវកំណត់ពីប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន (ប្រាក់រំដោះការរឹបអូសជាបណ្ដោះអាសន្ន)[38] ដើម្បីឱ្យកូនបំណុលទទួលបានការលុបចោលនូវភាពអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។ ការរឹបអូសជាបណ្ដោះអាសន្ន មានគោលបំណងរក្សាការពារនូវការអនុវត្ត ដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ហេតុនេះហើយការបើចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិដែលត្រូវទាមទារដែលពាក់ព័ន្ធត្រូវបានផ្ញើរ មានន័យថាប្រាក់ដែលត្រូវបានផ្ញើរ នឹងត្រូវ ជំនួសឱ្យវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន នោះម្ចាស់បំណុលនឹងមិនមានការខូតខាតធ្ងន់ធ្ងរ ហើយ រក្សាការពារក៏អាចលុបបានដែរ ។

**ក. ការដាក់ប្រាតិភោគ**

ការដាក់ប្រាតិភោគ ចំពោះដីកាសម្រេចប្រភេទនេះ តុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចដោយបង្គាប់ឱ្យដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ។ ការដាក់ប្រាតិភោគជាមធ្យោបាយសម្រាប់ធានាសំណងនៃការខូចខាតដល់កូនបំណុល ក្នុងករណីដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានលក្ខណៈផ្ទុយពីការពិត។

**ខ. ខ្លឹមសារ**

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺជាការធ្វើការចាត់ចែងក្នុងកម្រិតមួយនៃទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។

អត្ថិភាពនៃសិទ្ធិ លើបំណុលត្រូវតែកើតមាន ក្នុងករណីនេះ មានន័យថា ម្ចាស់បំណុលត្រូវតែបញ្ជាក់ដោយភស្តុតាង ដែលអាចបង្ហាញបានថា ខ្លួនពិតជា មានអត្ថិភាពនៃសិទ្ធិលើបំណុលពិតប្រាកដមែន។

ការរឹបអូសជាបណ្ដោះអាសន្ន គឺត្រូវរឹបអូសនូវទ្រព្យសម្បត្តិ(ជាក់លាក់)របស់កូនបំណុល ។ ទ្រព្យសម្បត្តិរបស់ កូនបំណុលអាច ជាចលនវត្ថុ អចលវត្ថុ ឬ សិទ្ធិលើបំណុលជាដើម។

**គ. ភាពចាំបាច់**

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនត្រឹមតែផ្អែកទៅលើអត្ថិភាពនៃសិទ្ធិ ដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ គឺត្រូវផ្អែកទៅលើភាពចាំបាច់រក្សាការពារផងដែរ ។

ភាពចាំបាច់ ដែលមានអត្ថិភាព គឺការអនុវត្តដោយបង្ខំនាពេលនាអនាគត និងមិនអាចធ្វើទៅបាន ឬ នឹងមានការលំបាក យ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ហេតុនេះត្រូវតែធ្វើឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែល ទើបអាចចាត់ទុកថា ការរក្សាការពារមានភាពចាំបាច់ ។

[37] មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

[38] មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ ២០០៦

រក្សាការពារ ត្រូវចាត់ទុកជាមានភាពចាំបាច់ ក្នុងករណី ដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូន បំណុល ទំនងជានឹងអាចធ្លាក់តម្លៃ ជាបរិមាណ ឬជាគុណភាព ឬ នឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្តូរជាប្រាក់ នៅក្នុង ការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការខ្ជះខ្ជាយ ការលក់ក្នុងតម្លៃមួយដែលថោក ការខូចខាត ការបំបាត់ ជាអាទិ៍។ ការរក្សាការពារ ក៏ត្រូវចាត់ទុកថាមានភាពចាំបាច់ដែរ ក្នុងករណីដែល កូនបំណុលបានគេច ខ្លួន ឬបានប្តូរលំនៅឋាន ឬមានលំនៅឋានមិនពិតប្រាកដ ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជា ឧបសគ្គ ចំពោះការអនុវត្តដោយបង្ខំ។ អសាធនភាពរបស់កូនបំណុលនៅពេលបច្ចុប្បន្ន មិនអាចធ្វើឱ្យរក្សា ការពារមានភាពចាំបាច់នោះទេ ។ ដោយឡែកប្រសិនបើ សាធនភាពរបស់កូនបំណុលមានភាពគ្រប់គ្រាន់ ហើយទំនងជានឹងអាចសម្រេចសិទ្ធិទាមទារបានដោយងាយស្រួលនោះ ភាពចាំបាច់នៃការរក្សាការពារក៏ត្រូវ បដិសេធផងដែរ ។ ការបដិសេធរបស់កូនបំណុលចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ឬឥរិយាបទរបស់កូន បំណុលក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចចំពោះសិទ្ធិនោះ ពុំមែនជាមូលហេតុ នៃការបញ្ជាក់អំពីភាពចាំបាច់នៃ ការរក្សាការពារទេ ព្រោះសកម្មភាពទាំងនោះមិនមែនជាឧបសគ្គ ចំពោះការអនុវត្តដោយបង្ខំឡើយ ។ ត្រង់ចំណុច នេះ បង្ហាញថាចរិកលក្ខណៈរបស់ភាពចាំបាច់ក្នុងការរក្សាការពារ គឺខុសគ្នាពី "ភាពចាំបាច់ដែលតម្រូវឱ្យធ្វើការ ទាមទារជាមុន" ដែលជាលក្ខខណ្ឌសម្រាប់ធ្វើបណ្តឹងទាមទារ ឱ្យផ្តល់តាវកាលិកនាពេលអនាគត ។ ទោះបីជា បានបំពេញតាមលក្ខខណ្ឌក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារ អាចនឹងត្រូវបានបដិសេធបានដែរ ដូចជា ករណីដែលសិទ្ធិលើបំណុលមានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬលើសិទ្ធិលើបំណុល បាន បំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយគ្មានលក្ខខណ្ឌ។

ការដែលយល់ឃើញថា ការអនុវត្តដោយបង្ខំ ដែលធ្វើនៅបរទេស នោះរក្សាការពារ ត្រូវចាត់ទុកជាមាន ភាពចាំបាច់។ ដូចជាកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និងការធ្វើអន្តោប្រវេសន៍ទៅ បរទេស ជាអាទិ៍។

**ឃ. នីតិវិធីនៃការចេញដីកាសម្រេច**

ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាឆន្ទានុសិទ្ធិរបស់ តុលាការគោលការណ៍ត្រូវធ្វើឡើងដោយសម្ងាត់ ប៉ុន្តែដើម្បីចេញដីកាសម្រេចទៅបាន អាចសាកសួរត្រឹមម្ចាស់ បំណុលបាន។

ការសាកសួរភាគី គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ហើយនៅក្នុងកនីតិវិធីនេះ ភាគីអាចធ្វើសេចក្តីថ្លែង ការណ៍របស់ខ្លួន ត្រង់ចំណុចវិវាទ ឬចំពោះករណីនីមួយៗ ជាលាយលក្ខអក្សរ ឬដោយផ្ទាល់មាត់បាន នៅក្នុងនីតិ វិធីសាកសួរ។

## ២. ដីកាសម្រេចចាត់ចែងបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នមិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំដែលពាក់ព័ន្ធនឹងសិទ្ធិលើបំណុលដែលត្រូវបានសម្រេចនាពេលអនាគតនោះទេ ផ្ទុយគ្នានឹងការរឹបអូសជាបណ្តោះអាសន្ន ដែលពុំមានការចាត់ចែងជាបណ្តោះអាសន្នណាមួយដែលត្រូវបាន គេកំណត់ចំនួនទឹកប្រាក់របស់កូនបំណុល ដើម្បីលុបចោលការអនុវត្តការចាត់ចែង នោះឡើយ។

**ក.ខ្លឹមសារ**

ដីកាសម្រេចប្រភេទនេះ ជាការកម្រិតនូវសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ គោលបំណងនៃដីកាសម្រេចនេះ គឺដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយហេតុនេះហើយទើបសិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្តោះអាសន្ន ដែលមានខ្លឹមសារជាការផ្លាស់ប្តូរ ឬគ្មានការផ្លាស់ប្តូរ ឬទំនាក់ទំនងនៃសិទ្ធិដែលមាននៅលើវត្ថុនោះ។ ខ្លឹមសារនៃដីកាសម្រេចអាចសម្រេចទៅបាន ដោយផ្អែកលើការទាមទារដែលបានសរសេរក្នុងពាក្យសុំ ប៉ុន្តែខ្លឹមសារនៃការទាមទារដែលម្ចាស់បំណុលបានសរសេរនោះ មិនសុទ្ធតែធ្វើការសម្រេចទៅតាមពាក្យសុំបានទាំងស្រុងនោះទេ វាគឺជាឆន្ទានុសិទ្ធិរបស់តុលាការ។

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់មិនអោយមានការចាត់ចែង ពោលគឺហាមឃាត់កូនបំណុលមិនអាចធ្វើអនុប្បទាន ធ្វើការផ្ទេរ ឬដាក់បញ្ចាំ ហ៊ីប៉ូតែក ជួល និងចាត់ចែងគ្រប់ប្រភេទចំពោះអចលនវត្ថុ ដោយផ្អែកលើកម្មសិទ្ធិ។

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ គឺជាការហាមឃាត់កូនបំណុលមិនឱ្យផ្លាស់ប្តូរអ្នកកាន់កាប់ ឬផ្ទេរនៃវត្ថុនោះ ហើយបង្គាប់ឱ្យកូនបំណុលផ្ទេរវត្ថុដែលជាកម្មវត្ថុខាងលើនេះទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់លើវត្ថុនោះ និងបង្គាប់ឱ្យអាជ្ញាសាលាគ្រប់គ្រងវត្ថុ និងប្រកាសជាសាធារណៈ។

**ខ.ភាពចាំបាច់**

ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវបានទទួលស្គាល់ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងអាចមានការលំបាកក្នុងការអនុវត្តសិទ្ធិ ដោយសារតែមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។[39] ករណីនេះផងដែរ រួមមានករណីដែលមានហានិភ័យនៃការខូចខាត ការគៃបំបាត់ ការផ្ទេរ ការរាំងស្ទះ រារាំងសិទ្ធិ លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយកូនបំណុល ក្នុងករណីដែលបុគ្គលណាម្នាក់កំពុងបន្តដំណើរការនៃការសាងសង់ ក្នុងខណៈដែល

[39] កថាខណ្ឌទី២ មាត្រា ៥៣១ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាលឱ្យប្រើ ០៦ កក្កដា ២០០៦

មានការទាមទារឱ្យដកចេញនូវការសាងសង់នោះ បុគ្គលម្នាក់នាំបុគ្គលម្នាក់ផ្សេងទៀតរួមទាំងឥវ៉ាន់របស់គេ មករស់នៅជាមួយ ក្នុងខណៈដែលមានការទាមទារ ឱ្យបណ្តេញចេញពីផ្ទះនោះ ករណីដែលបុគ្គលម្នាក់ចាប់ផ្តើមការសាបព្រួស ក្នុងខណៈដែលមានការទាមទារឱ្យប្រគល់ដីកសិកម្មនោះ ជាអាទិ៍។

**គ. នីតិវិធីនៃការចេញដីកាសម្រេច**

នីតិវិធី នៃការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះកម្មវត្ថុនៃវិវាទត្រូវបានអនុវត្តដូចគ្នាផងដែរចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទោះបីជាគោលបំណងនៃដីកាទាំងពីរនេះមានភាពខុសគ្នាក៏ដោយ គោលការណ៍នៃដីការក្សាការពារ គឺធ្វើឡើងដោយសម្ងាត់ បន្ទាន់ និងឆាប់រហ័ស ដូចគ្នា។

**៣. ដីកាសម្រេចចាត់ចែងបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន**

តុលាការកំណត់នូវឋានៈជាបណ្តោះអាសន្ន ដោយបង្គាប់ឱ្យកូនបំណុលបង់ថ្លៃឈ្នួលដល់ម្ចាស់បំណុលរៀងរាល់ខែ រហូតដល់សាលក្រមចូលជាស្ថាពរ (ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាអ្នកជួល)។

**ក. ខ្លឹមសារ**

ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាត ឬគ្រោះថ្នាក់បន្ទាន់ណាមួយដែលអាចកើតមានឡើងចំពោះម្ចាស់បំណុល រវាងទំនាក់ទំនងគតិយុត្តដែលមានវិវាទ។[40]

សិទ្ធិលើទ្រព្យសម្បត្តិ ឬសិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល ដែលត្រូវបានរក្សាការពារដោយសិទ្ធិអាចជាកម្មសិទ្ធិ សិទ្ធិកាន់កាប់ សិទ្ធិលើនាម សេរភាព ទំនាក់ទំនងគតិយុត្តិដែលនៅជាប់បន្តដូចជា ភតិសន្យា កិច្ចសន្យាការងារ និងកិច្ចសន្យាផ្សេងៗទៀត ជាអាទិ៍។

ជាឧទាហរណ៍ ការរក្សាការពារឋានៈជាបុគ្គលិក នោះគឺជាការចាត់ចែងជាបណ្តោះអាសន្ននៃការបង់ប្រាក់ឈ្នួលជាបណ្តោះអាសន្ន។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការអនុវត្តហ៊ីប៉ូតែក។ ការកំណត់ពីឋានៈ ដែលមានសិទ្ធិក្នុងកិច្ចសន្យាការងាររបស់ម្ចាស់បំណុលចំពោះកូនបំណុលជាអាទិ៍។

**ខ. ភាពចាំបាច់**

ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ត្រូវបានគេយល់ឃើញថា មានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធរ ឬគ្រោះថ្នាក់បន្ទាន់នឹងកើតឡើងចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។[41]

[40] កថាខណ្ឌទី៣ មាត្រា ៥៣១ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[41] កថាខណ្ឌទី២ មាត្រា ៥៤៨ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

### គ. នីតិវិធីនៃការចេញដីកាសម្រេច

ដីកាសម្រេចចាត់ចែងបណ្តោះអាសន្នចំពោះឋានៈបុគ្គល មិនអាចចេញបានឡើយ ប្រសិនបើគ្មានការឆ្លងកាត់នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ឬការសាកសួរដែលកូនបំណុលអាចចូលរួមបាន។[42] ម្យ៉ាងវិញទៀត ការចាត់ចែងជាបណ្តោះអាសន្ន ត្រូវធ្វើជាសម្ងាត់ដូចករណីនៃការរឹបអូសជាបណ្តោះអាសន្នក៏ដោយ ក្នុងនោះ ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបណ្តោះអាសន្ន ផលប្រយោជន៍របស់ម្ចាស់បំណុលនៅតែត្រូវការពារទោះបីជា គ្មានការវិនិច្ឆ័យជាសម្ងាត់ក៏ដោយ មិនតែប៉ុណ្ណោះ នីតិវិធីនេះធ្វើឡើងដោយសម្ងាត់ វាអាចនឹងមានការប៉ះពាល់ធ្ងន់ធ្ងរចំពោះកូនបំណុល។ ហេតុដូច្នេះ ទើបគេផ្តល់ឱកាសឱ្យកូនបំណុល ក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នប្រភេទនេះ។ ក៏ប៉ុន្តែ កថាខណ្ឌទី ៤ មាត្រា ៥៤៨ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ផងដែរថា ក្នុងករណីដែលមានស្ថានភាពពិសេសដែលនាំអោយពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ជាអាទិ៍ នោះដីកាសម្រេចចាត់ចែង ជាបណ្តោះអាសន្នអាចចេញបាន ដោយមិនចាំបាច់ឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់នោះទេ។

### ៤ .ដីកាសម្រេចលើកចោលពាក្យសុំ

ក្នុងករណីដែល តុលាការសម្រេចធ្វើការលើកចោលពាក្យសុំ តុលាការត្រូវបញ្ជូនដីកាសម្រេចនោះទៅម្ចាស់បំណុល ដើម្បីផ្តល់ដំណឹងជូនម្ចាស់បំណុល ក្នុងការធ្វើបណ្តឹងជំទាស់នូវសេចក្តីសម្រេចរបស់តុលាការប្រសិនជាម្ចាស់បំណុលមិនសុខចិត្តនឹងសេចក្តីសម្រេច។ តុលាការមិនចាំបាច់ធ្វើការជូនដំណឹងទៅកូនបំណុលនោះទេ ក្នុងករណីដែលលើកចោលពាក្យសុំ ដោយសារតែពុំមានការប៉ះពាល់ ឬខូចខាតដល់ប្រយោជន៍របស់កូនបំណុលឡើយ។ ផ្ទុយទៅវិញ បើសិនជាបានឆ្លងកាត់នីតិវិធីសាកសួរ ឬការទាញហេតុផលដោយផ្ទាល់មាត់ នោះតុលាការត្រូវតែជូនដំណឹងទៅភាគីទាំងអស់។[43]

## ផ្នែកទី៣៖ ការអនុវត្តដីកាសម្រេច

### ១ .លក្ខខណ្ឌក្នុងការអនុវត្ត

ក្រោយពេលទទួលបានដីការក្សាការពាររួចមក ដីកាសម្រេចនេះមានអនុភាពអនុវត្តភ្លាម[44]។ចំពោះការកំណត់បែបនេះគឺ ជាការគិតគូរដល់ហានិភ័យរបស់ម្ចាស់បំណុលដែលនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តនាពេលអនាគត ប្រសិនបើមិនមានវិធានការណ៍អន្តរាគមន៍ទាន់ពេលវេលាទេ ឬ អាចនិយាយបានថាបើ

[42] កថាខណ្ឌទី៤ មាត្រា ៥៤៨ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[43] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេនី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[44] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេនី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

មិនអោយដីកាសម្រេចនេះមានអនុភាពភ្លាមទេ វាមិនឆ្លើយតបទៅនឹងភាពចាំបាច់នៃការរក្សាការពារសិទ្ធិទាមទាររបស់ម្ចាស់បំណុលក្នុងការអនុវត្តចំពោះកូនបំណុល នៃការអនុវត្តឡើយ។ទោះបីជាមានដីការក្សាការពារយ៉ាងណាក៏ដោយបើសិនជាម្ចាស់បំណុលមិនបានដាក់ពាក្យសុំអនុវត្តជាបន្ទាន់ទៅតុលាការអនុវត្ត ឬ អាជ្ញាសាលានៃវត្ថុដែលជាកម្មវត្ថុនៃការរក្សាការពារស្ថិតនៅទេ ដីកាសម្រេចនោះគឺគ្មានន័យ។ដោយសារថាបើហួសអំឡុងពេល ២សប្តាហ៍នៃការអនុវត្តដែលបានកំណត់ដែលបានកំណត់នៅក្នុងច្បាប់ ដីកាសម្រេចនោះមិនអាចអនុវត្តបានទៀតទេ[45]។ពាក្យសុំអោយអនុវត្តដីកាសម្រេចរក្សាការពារត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយត្រូវភ្ជាប់មកជាមួយលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអនុភាពអនុវត្ត។អ្នកដាក់ពាក្យសុំមិនបាច់ស្នើសុំរូបមន្តអនុវត្តទេពីព្រោះថាការរក្សាការពារជាបញ្ហាបន្ទាន់បង្ខំហេតុនេះត្រូវអនុវត្តអោយបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។ក៏ប៉ុន្តែបើសិនជាការអនុវត្តចំពោះ ឬ សម្រាប់ជនក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងដីការសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីការសម្រេចរក្សាការពារ ដែលភ្ជាប់ជាមួយនិងរូបមន្តអនុវត្ត[46]។ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមានមេធាវីដែលតំណាងខ្លួន ពាក្យសុំអនុវត្តនោះត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិផងដែរ។ប៉ុន្តែបើមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះរួចហើយនៅក្នុងបណ្តឹងអង្គសេចក្តី ហេតុនេះមិនចាំបាច់ភ្ជាប់មកជាមួយម្តងទៀត។

## ២.ពាក្យសុំអនុវត្តដីកាសម្រេចចាត់ចែងរក្សាការពារ

ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំនេះ ត្រូវអនុលោមទៅតាមការដាក់ពាក្យសុំអោយអនុវត្តដោយបង្ខំ[47]ដែលមានទម្រង់ដូចខាងក្រោមនេះ៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលដែលត្រូវអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត។
- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តរក្សាការពារ និងវិធីអនុវត្តរក្សាការពារដែលម្ចាស់បំណុលនៃការអនុវត្តសុំ។
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ។

នៅក្នុងពាក្យសុំអោយអនុវត្តចំពោះចលនវត្ថុត្រូវសរសេរអំពីទីកន្លែងចលនវត្ថុដែលត្រូវរឹបអូសជា

[45] កថាខណ្ឌទី២ មាត្រា ៥៥៦ក្រមនីតិវិធីរដ្ឋប្បវេនី ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦
[46] មាត្រា ៥៦២ កថាខណ្ឌទី១ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦
[47] មាត្រា ៥៦៥ ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃកន្ថី៦ ដោយអនុលោមតាមមាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

បណ្តោះអាសន្ននោះស្ថិតនៅ។

### ៣. ពន្ធនៃពាក្យសុំអនុវត្ត

នៅពេលដាក់ពាក្យសុំឱ្យអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធពាក្យសុំ។ក្នុងករណីដែលតុលារការអនុវត្តជាតុលាការដែលមានសមត្ថកិច្ច អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន១០០០០(មួយមឺុន)រៀលទៅតុលការអនុវត្ត[48]។ក្នុងករណីដែលស្ថាប័នអនុវត្តជាអាជ្ញាសាលាដូចជា ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ការចាត់ចែងជាបណ្តោះអាសន្នជាអាទិ៍ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០ (ប្រាំពាន់) រៀលចំពោះអាជ្ញាសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។

នៅពេលដែលម្ចាស់បំណុលដាក់ពាក្យសុំអោយអនុវត្តដីកាសម្រេចរក្សាការពារ ត្រូវបង់សាហ៊ុយចាំបាច់ជាមុន ដែលកំណត់ដោយតុលាការអនុវត្ត ឬ អាជ្ញាសាលាសម្រាប់ដំណើរការអនុវត្ត។ផ្ទុយមកវិញ ប្រសិនបើអ្នកដាក់ពាក្យសុំអនុវត្តមិនបានបង់សាហ៊ុយជាមុនទេ នោះតុលាការអនុវត្តរក្សាការពារអាចលើកពាក្យសុំនោះចោល ឬ អាចលុបចោលនូវនីតិវិធីនៃការអនុវត្តការរក្សាការពារបាន[49]។

### ៤.ស្ថាប័នមានសមត្ថកិច្ច

#### ក. អាជ្ញាសាលា

អាជ្ញាសាលាគឺជាមន្ត្រីអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។ ដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត[50] អាជ្ញាសាលាមានតួនាទី និងភារកិច្ចច្រើនក្នុងនោះ ពេលខ្លះអាជ្ញាសាលាអនុវត្តតួនាទីក្នុងនាមជាស្ថាប័នឯករាជ្យ និងពេលខ្លះអាជ្ញាសាលាអនុវត្តកិច្ចការជាជំនួយការរបស់តុលាការ។

នៅក្នុងការអនុវត្តដោយបង្ខំ ឬ រឹបអូសជាបណ្តោះអាសន្នដែលមានគោលបំណងអោយសងជាប្រាក់ អាជ្ញាសាលាមានសមត្ថកិច្ចចំពោះតែចលនវត្ថុតែប៉ុណ្ណោះ[51]។ការចាត់ចែងរក្សាការពារចំណែកឯការអនុវត្តដោយបង្ខំ ឬ ចាត់ចែងរក្សាការពារ ដែលគ្មានគោលបំណងអោយសងជាប្រាក់ទេ អាជ្ញាសាលាអាចអនុវត្តសិទ្ធិអំណាចរបស់ខ្លួន តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្នុងការទាមទារឲប្រគល់ ចលនវត្ថុ អចលនវត្ថុ និង នាវាបាន[52]។

---

[48] មាត្រា ៥៦៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[49] មាត្រា ៥៣៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[50] ប្រកាសលេខ ៣០ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៧

[51] មាត្រា ៣៨៤ និង មាត្រា៥០០ និងមាត្រា៥៦៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

52 មាត្រា ៥២៤ និងមាត្រា ៥២៥ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

### ខ. តុលាការអនុវត្ត

តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តរក្សាការពារ[53]។ តុលាការអនុវត្តរក្សាការពារ ជាតុលាការសាលាដំបូងតាមរាជធានីខេត្តនីមួយៗដោយហេតុថាតុលាការនេះ មានសមត្ថកិច្ចនៅក្នុងដែនដីនៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ។តុលាការអនុវត្តមានសមត្ថកិច្ចអនុវត្តរក្សាការពារចំពោះ អចលនវត្ថុ សិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និង នាវា[54]។

## ៥ . ការរឹបអូសបណ្ដោះអាសន្ន

### ក.ចលនវត្ថុ និង អចលនវត្ថុ

- ចលនវត្ថុ សំដៅទៅលើវត្ថុណាដែលអាចផ្លាស់ទីបានតាមការប្រើប្រាស់ធម្មតានៃវត្ថុដោយការផ្លាស់ទី ឬ ចល័តបាន ដូចជា ឡាន ម៉ូតូ តុ ទូ ជាដើម[55]។ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនាវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។នៅក្នុងករណីការឹបអូសចលនាវត្ថុដូចជាគ្រឿងអលង្កា ឬ របស់របរផ្សេងទៀតដែលជាកម្មវត្ថុមានតម្លៃហើយស្រួលដឹកជញ្ជូនផងនោះ ជាធម្មតាអាជ្ញាសាលាត្រូវរក្សាទុកវត្ថុនោះដោយខ្លួនឯង។

ប៉ុន្តែនៅក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ជាប្រាក់ អាជ្ញាសាលាមិនដកហូតទុក ឬ ឲកូនបំណុលរក្សាទុកប្រាក់នោះទេ តែអាជ្ញាសាលាតត្រូវផ្ញើរប្រាក់នោះទៅតុលាការដែលខ្លួនស្ថិតនៅ[56]។ម៉្យាងវិញទៀត បើសិនជាវត្ថុដែលអាជ្ញាសាលាកាន់កាប់ងាយ និង ខូច ឬ មានការបារម្ភថាចលនាវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ននោះនឹងចុះតម្លៃយ៉ាងខ្លាំង ឬ ត្រូវចំណាយសាហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមវិធីនៃការលក់ដោយបង្ខំចំពោះចលនវត្ថុតាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការអនុវត្តបាន។នៅក្នុងករណីនេះ ប្រាក់ដែលទទួលបានពីការលក់ត្រូវយកទៅផ្ញើរនៅតុលាការនៃសាលាដំបូងអាជ្ញាសាលានោះស្ថិតនៅ[57]។

ឧទាហរណ៍

មិនតែប៉ុណ្ណោះអាជ្ញាសាលាក៏មិនអាចរឹបអូសតាមតែចិត្តខ្លួនឯងបាននោះដែរមានន័យថាគាត់ត្រូវប៉ាន់

[53] មាត្រា ៥៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[54] ការអនុវត្តចំពោះសិទ្ធិលើបំណុល និងការអនុវត្តលើទ្រព្យសម្បត្តិផ្សេងទៀត(មាត្រា៥០២ និងមាត្រា ៥០៥)អចលនវត្ថុ(មាត្រា៤១៧ និងមាត្រា៥០៩) នាវា (មាត្រា៤៥៤ និងមាត្រា៥២១ ) នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[55] ចលនវត្ថុសំដៅវត្ថុក្រៅពីអចលនាវត្ថុ (មាត្រា ១២០) នៃក្រមរដ្ឋប្បវេណី ៨ ធ្នូ ២០០៧

[56] មាត្រា ៥៦៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[57] មាត្រា ៥៦៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

ប្រមាណចំពោះការរឹបអូសនោះយ៉ាងម៉ត់ចត់ដូចជា ករណីនៃការអនុវត្តរឹបអូសចលនាវត្ថុ មិនត្រូវធ្វើអោយហួសកម្រិតពេកនៃសិទ្ធិទាមទារបស់ម្ចាស់បំណុលនៃការអនុវត្តឡើយ។

នៅពេលដែលបានដឹងថា ការរឹបអូសលើសពីកម្រិតនៃការទាមទាររបស់ម្ចាស់បំណុល នៅក្រោយពេលដែលបានរឹបអូសរួចហើយ អាជ្ញាសាលាត្រូវលុបចោលការរឹបអូសត្រឹមតែផ្នែកណាដែលបានហួសកម្រិតនោះ។ ម៉្យាងទៀតអាជ្ញាសាលាមិនត្រូវរឹបអូសសោះឡើយបើប៉ាន់ប្រមាណសេសសល់ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ។

នៅក្នុងករណីរឹបអូសជាបណ្តោះអាសន្នចំពោះរថយន្ត ឬ ទោចក្រយានយន្តដែលមានការចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្តាក់អោយស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុការណ៍ដែលបានរឹបអូសនោះ ចូលទៅក្នុងសៀវភៅបញ្ជី។ការរឹបអូសនឹងមានអានុភាពនៅពេលដែលបានសរសេរនូវហេតុការណ៍នៃការរឹបអូសនោះ ចូលទៅក្នុងសៀវភៅចុះបញ្ជី[58]។

អចលនវត្ថុ នៅក្នុងក្រមរដ្ឋប្បវេណីអចលនាវត្ថុសំដៅលើ ដីធ្លី និង វត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ទីកន្លែងបានដូចជា អាគារ សំណង់ រុក្ខជាតិ ជាអាទិ៍[59]។នៅក្នុងការអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុសំដៅលើអគារដែលត្រូវបានចុះបញ្ជី ចំណែកឯកម្មសិទ្ធិអវិភាគលើដី ឬ អគារនោះ សិទ្ធិជួល អចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះ ដែលជាសិទ្ធិរួម[60]។

តុលាការដែលបានចេញដីកាសម្រេចអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ[61]។ចំណែកក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ហើយការផ្ទុកផ្តាក់នេះត្រូវអនុវត្តអោយបានឆាប់រហ័ស បន្ទាប់ពីដាក់ពាក្យសុំអនុវត្ត។អានុភាពនៃការរក្សាការពារនឹងកើតមាននៅពេលបានចុះបញ្ជីអំពីការរឹបអូសជា បណ្តោះអាសន្ន។ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីមានដូចជា រដ្ឋបាលសុរិយោដី រាជធានី ខេត្ត[62]។ ការផ្ទុកផ្តាក់នេះក្រឡាបញ្ជីត្រូវប្រគល់ឯកសារមួយចំនួនឲទៅស្ថាប័នដែលមានសមត្ថកិច្ច ដើម្បីធ្វើការចុះបញ្ជីមានដូចជា៖

- លិខិតផ្ទុកផ្តាក់ចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ
- ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

[58] មាត្រា ៣៨៧ កថាខណ្ឌទី១ និងទី២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[59] មាត្រា ១២០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ៨ ធ្នូ ឆ្នាំ ២០០៦

[60] មាត្រា ៤១៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[61] មាត្រា ៥៦៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[62] ប្រកាស២នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនាវត្ថុទាក់ទងនិងក្រមនីតិវិធីរដ្ឋប្បវេណីលេខ៣ ឧសភា ឆ្នាំ ២០១១

ចំណុចដែលត្រូវសរសេរនៅក្នុងលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីមានដូចខាងក្រោម[63]៖

1 . អត្តសញ្ញាណនៃអចលនវត្ថុ(លេខក្បាលបញ្ជី ឬ លេខប័ណ្ណ និងទីតាំង)

2 . ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនាវត្ថុ និងអាសយដ្ឋាន

3. គោលបំណងនៃការចុះបញ្ជី (រឹបអូសជាបណ្ដោះអាសន្នកម្មសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីអចលនវត្ថុ)

4 . មូលហេតុ(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន លេខ ចុះថ្ងៃទី ខែ ឆ្នាំ និង ឈ្មោះរបស់តុលាការ)

5 . ឈ្មោះម្ចាស់បំណុល និងអាសយដ្ឋាន។

6 . ឈ្មោះកូនបំណុល និង អាសយដ្ឋាន។

ក្រោយពីបានចុះបញ្ជីរួចរាល់ហើយ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារសម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី[64]។ក្រឡាបញ្ជីត្រូវពិនិត្យទៅលើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី ហើយអាចស្នើរឲសុរិយោដីធ្វើការកែតម្រូវបាន ប្រសិនបើមានភាពចាំបាច់។ប៉ុន្តែប្រសិនបើអចលនវត្ថុដែលត្រូវបានរឹបអូសមិនទាន់បានចុះបញ្ជីទេនោះ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឲស្ថាប័ន ដែលមានសមត្ថកិច្ចធ្វើការចុះបញ្ជីអចលនវត្ថុនោះព្រមទាំងការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នផង។

ការរឹបអូសជាបណ្ដោះអាសន្ននេះពុំត្រូវបានរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ឬ អាស្រ័យផលពីអចលវត្ថុតាមវិធីប្រើធម្មតាឡើយ[65]។ការប្រើប្រាស់និងអាស្រ័យផលតាមវិធីប្រើប្រាស់ធម្មតា មានន័យថាជាការប្រើប្រាស់អចលនវត្ថុដោយខ្លួនឯង ឬ ការទទួលថ្លៃឈ្នួលនៃអចលនវត្ថុដែលខ្លួនបានជួលឲគេហើយជាដើម[66]។

យ៉ាងណាមិញ អចលនវត្ថុនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្នមិនប្រាកដថា មានតែម្ចាស់បំណុលនៃការអនុវត្តផ្សេងទៀត បានដាក់ពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្នលើអចលនវត្ថុនោះដែរ ចំពោះអចលនវត្ថុដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបាន សម្រេចរក្សាហើយ ហើយតុលាការទទួលស្គាល់ពាក្យសុំក្រោយ តុលាការនេះត្រូវចេញដីកាសម្រេចចាប់ផ្ដើមរឹបអូសជាបណ្ដោះអាសន្នថ្មីមួយទៀត។ករណីនេះតុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដែលទាក់ទងនិងដីកាសម្រេចចាប់ផ្ដើមមុន[67]។បើមានភាពច្បាស់លាស់អំពីស្ថានភាពដែលបានបាត់បង់អចលវត្ថុ ឬ ស្ថានភាពផ្សេងទៀត

---

[63] ប្រកាស១៦នៃប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនាវត្ថុទាក់ទងនិងក្រមរដ្ឋប្បវេណី ៣ ឧសភា ឆ្នាំ ២០១១

[64] មាត្រា ៥៦៧ កថាខណ្ឌទី៤ និងមាត្រា ៤២០ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[65] មាត្រា ៤២១ កថាខណ្ឌទី៣ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[66] សេចក្ដីកំណត់មាត្រា ៤២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

[67] មាត្រា ៦២១ កថាខណ្ឌទី១(ដីការសម្រេចចាប់ផ្ដើមត្រួតគ្នា) នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

ដែលរារាំងការផ្ទេរអចលនវត្ថុ ដោយការលក់នាពេលអនាគត តុលាការអនុវត្តត្រូវលុបចោលនីតិវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ននេះ។

**ខ.សិទ្ធិលើបំណុល និងទ្រព្យសម្បត្តិ**

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល និង ទ្រព្យសម្បត្តិផ្សេងទៀតត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី៣ សងទៅកូនបំណុល[68]។ដីកាសម្រេចរឹបអូសត្រូវធ្វើឡើងដោយមិនចាំបាច់សួរកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី៣នោះទេ[69]។ប៉ុន្តែក្នុងករណីដែលពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវបានដកវិញ ឬ បើមានដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តក្រឡាបញ្ជីត្រូវជូនដំណឹងនេះទៅឱ្យកូនបំណុលទី៣នោះ[70]។ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី ដែលត្រូវបានរឹបអូសក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមាន សមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថាសិទ្ធិលើបំណុលនោះ ត្រូវបានរឹបអូសហើយ[71]។ជាមួយគ្នានេះដែរតុលាការអនុវត្តអាចចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលទាំងអស់ដែលត្រូវរឹបអូសនោះបាន។ពេលដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ត្រូវបានរឹបអូស កូនបំណុលទី៣ អាចធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុង ចំណោមសិទ្ធិលើបំណុលនោះ ឬ ប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនោះទាំងអស់នៅតុលាការអនុវត្តបាន ហើយការអនុវត្តចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្រៅពីអចលនវត្ថុ នាវាចលនវត្ថុ និងសិទ្ធិលើបំណុលត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែមានបញ្ញត្តិពិសេស។

**គ. នាវា**

នាវាសំដៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០ (ម្ភៃ)តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងជលយានដែលមានចំណុះសរុបជាតោន ក្រោម ២០ (ម្ភៃ) តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[72]។

ពាក្យសុំអោយអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ត្រូវដាក់ទៅតុលាការអនុវត្តដែលមានសមត្ថកិច្ចក្រោយពីទទួលបានដីកាសម្រេចរឹបអូសហើយ។ក្រៅពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំម្ចាស់បំណុលនៃការអនុ

[68] មាត្រា ៥៦៦ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[69] មាត្រា ៤០៣ កថាខណ្ឌទី ៦ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[70] មាត្រា ៤០៨ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[71] មាត្រា ៤០៣ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[72] មាត្រា ៤៥៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

វត្តត្រូវសរសេរអំពីទីកន្លែងដែលនាវានោះស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវា និងទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន[73]។ មួយវិញទៀត ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយនូវឯកសារដែលបានកំណត់ដូចខាងក្រោមៈ

- ចំពោះនាវាដែលបានចុះបញ្ជី គឺឯកសារចម្លងនៃសៀវភៅចុះបញ្ជីដែលមានសេចក្តីបញ្ជាក់
- ចំពោះនាវាកម្ពុជាដែលមិនបានចុះបញ្ជី ឬនាវាផ្សេងទៀតក្រៅពីនាវាកម្ពុជាដែលមានឯកសារបញ្ជាក់ថា នាវានោះមានទម្ងន់ស្មើនឹង ឬ លើសពី២០ (ម្ភៃ)តោន និងឯកសារបញ្ជាក់ថានាវានោះស្ថិតនៅ ជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[74]។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ននាវាអាចធ្វើបាន ២ (ពីរ) របៀបគឺ

១ . អាចធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ

២ .តាមរបៀបដែលបង្គាប់អោយអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវាហើយផ្តល់លិខិតនោះទៅតុលាការអនុវត្តរក្សាការពារ ហើយវិធីទាំងពីរនេះក៏អាចអនុវត្តរួមគ្នាផងដែរ។

ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះនាវា គឺក្រឡាបញ្ជីនៃតុលាការដែលមានសមត្ថកិច្ចរក្សាការពារជាអ្នកទទួលបន្ទុកអំពីការចាត់ចែងអំពីការចុះបញ្ជីនោះ។

ក្រោយពេលបានធ្វើការផ្ទុកផ្តាក់ឲស្ថាប័ន ដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសរួចជាស្រេចហើយតុលាការអាចធ្វើការការជ្រើសតាំងអ្នកគ្រប់គ្រងថៃរក្សានាវា បើសិនជាមានភាពចាំបាច់កក្នុងការរក្សាការពារចំពោះនាវាដើម្បីអនុវត្តដោយបង្ខំនាពេលអនាគត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន[75]។អ្នកគ្រប់គ្រងថៃរក្សានាវា ត្រូវថៃរក្សាអោយបានប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយ សុច្ចរិត មានន័យថាមើលថៃរក្សាអោយដូចជាទ្រព្យសម្បត្តិរបស់ខ្លួន។នៅពេលបញ្ចប់ភារកិច្ចអ្នកគ្រប់គ្រងថៃរក្សាត្រូវរាយការណ៍អំពីចំណូលចំណាយទៅតុលាការអនុវត្តដោយគ្មានការយឺតយ៉ាវ។នៅក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានដកពាក្យសុំអនុវត្ត ឬ ក៏តុលាការសម្រេចចេញដីកាលុបចោលការរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲស្ថាប័នដែលមានសមត្ថកិច្ចលុបចោលការរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲស្ថាប័ន

[73] មាត្រា ៥៥៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[74] មាត្រា ៥៥៥ កថាខណ្ឌទី៣ ចំណុច កនិងខ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ ២០០៦

[75] មាត្រា៥៦៨ កថាខណ្ឌ៣ ចំណុច ក និងខ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

ដែលមានសមត្ថកិច្ចលុបចោលការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីការសម្រេចចាប់ផ្តើមនោះ[76]។

## ៦.ការចាត់ចែងជាបណ្តោះអាសន្ន

### ក. ប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្ន

ការចាត់ចែងជាបណ្តោះអាសន្នមានពីរប្រភេទ៖ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[77]។ទោះបីជាមានគោលបំណង និង ចរិកលក្ខណៈខុសគ្នាក៏ដោយ ក៏ចាត់ចែងជាបណ្តោះអាសន្នទាំងពីរនេះ ស្ថិតនៅក្នុងប្រភេទនៃការចាត់ចែងរក្សាការពារ ហើយសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ដូចគ្នា។ ហេតុនេះហើយ ការចាត់ចែងជាបណ្តោះអាសន្នទាំងពីរនេះ ត្រូវធ្វើតាមនីតិវិធីដូចគ្នា។

### ខ. លក្ខខណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

សិទ្ធិដែលត្រូវបានរក្សាការពារ ៖ គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនោះ។ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយបានចាត់ចែងជាបណ្តោះអាសន្ននេះ ត្រូវមានខ្លឹមសារជាការផ្លាស់ប្តូរ ឬ មិនផ្លាស់ប្តូរនូវស្ថានភាពជាក់ស្តែង ឬ ទំនាក់ទំនងសិទ្ធិដែលមានលើវត្ថុ[78]។សិទ្ធិដែលត្រូវបានរក្សាការពាររួមមាន សិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារឱ្យបណ្តេញបុគ្គលចេញពីដី ឬ អាគារ សិទ្ធិទាមទារឱ្យដកចេញនូវការសាងសង់ សិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារមិនអោយធ្វើសកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់វត្ថុជាអាទិ៍។

**ឧទាហរណ៍ ៖** គំរូនៃការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ រួមមាន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ដើម្បីរក្សាការពារទាមទារឱ្យបណ្តេញចេញពីអចលនវត្ថុនោះ ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុជាអាទិ៍ ។ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដែលមានគោលបំណងជាការចាត់ចែង ដូចជាអនុប្បទាន[79]និងការប្រមូល ត្រូវចាត់ទុកដូចជាវត្ថុ ហើយ

[76] មាត្រា៥៦៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

[77] មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

78វត្ថុនេះ ហៅថា "វត្ថុដែលជាកម្មវត្ថុនៃវិវា"

[79] អនុប្បទានការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអននុប្បទាយី ទៅអោយបុគ្គលម្នាក់ទៀត ដែលជាអនុប្បទានិក ទំព័រ ២៧ នៃសន្ទានុក្រម ផ្នែករដ្ឋប្បវេណីក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៦។

ដោយហេតុនេះ អាចក្លាយជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្នប្រភេទនេះបាន។

**គ. លក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន**

សិទ្ធិដែលត្រូវបានរក្សាការពារ ៖ ការចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន រួមបញ្ចូលនូវការចាត់ចែងជាច្រើនប្រភេទ។ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្តោះអាសន្នប្រភេតទនេះក៏មានច្រើនដែរសិទ្ធិដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬ សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល[80]។

**ឧទាហរណ៍ ៖** ទំនាក់ទំនងសិទ្ធិផ្តាច់មុខ ដូចជាកម្មសិទ្ធិកាន់កាប់ សេវភាព សិទ្ធិលើនាម និង សិទ្ធិលើប្រកាសនីយប័ត្រក្កកម្ម ទំនាក់ទំនងបន្តរវាងសិទ្ធិប្រត្យក្សដូចជា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា និង កម្មសិទ្ធិអវិភាគ ទំនាក់ទំនងគតិយុត្តដែលបន្ត ដូចជាកិច្ចសន្យាក្រុមហ៊ុន ភតិសន្យាការងារ និងការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) និង ទំនាក់ទំនងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងរវាងឪពុកម្តាយ និង កូន។ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប្រសិនបើគោលបំណងនៃការរក្សាការពារ មិនមែនដើម្បីរក្សាការពារ មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំ នាពេលអនាគតទេ តែគឺដើម្បីទប់ស្កាត់ និងដកចេញនូវគ្រោះថ្នាក់ ឬការខូចខាតពិសេសដែលកើតឡើង ពីការមិនអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារនោះ គេអាចទាមទារ ឱ្យផ្តល់តាវការលិកទាំងស្រុង ឬ មួយផ្នែកតាមមនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នបាន។

**ភាពចាំបាច់នៃការរក្សាការពារ ៖** ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[81]។

**ឧទាហរណ៍ ៖** ករណីដែលខូចខាតដែលមិនអាចជួសជុលបាន កំពុងកើតឡើងចំពោះម្ចាស់បំណុល ដោយសាការចុះផ្សាយជាសាធារណៈនូវអត្ថបទទស្សនាវដ្តីដែលមានលក្ខណៈជាការបរិហាកេរ្តិ៍ ករណីដែលមានការបារម្ភអំពីគ្រោះថ្នាក់ដល់សុខភាពរបស់ម្ចាស់បំណុល ដែលបង្កឡើងដោយសម្លេងនៃការសាងសង់ជាអាទិ៍។

**៧.ការអនុវត្ត**

ខុសគ្នាពីការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន មិនអាចបំពេញគោលបំណង

[80] សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល គឺជាសិទ្ធិនៃទំនាក់ទំនងនៃក្រុមគ្រួសារមានដូចជា ប្តីប្រពន្ធ ឪពុកម្តាយកូន មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីទាក់ទងនឹងឋានៈបុគ្គល និង សេចក្តីកំណត់ចំពោះមាត្រានីមួយៗឆ្នាំ២០០៤។

[81] មាត្រា ៥៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

របស់វា ដោយវិធីតែមួយនៃការរឹបអូសយកទ្រព្យសម្បត្តិនោះឡើយ។ ហេតុនេះហើយវិធី និង កម្រិតនៃការចាត់ចែងជាបណ្តោះអាសន្ន អាចនឹងមិនអាស្រ័យទៅតាមដំណាក់កាលនៃការអនុវត្តទេ តែត្រូវកំណត់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន គ្រាន់តែបង្កើតនូវឋានៈគតិយុត្តនៅក្នុងការសម្រេចសេចក្តីប៉ុណ្ណោះ គឺមិនបង្កើតបញ្ហានៃការអនុវត្តទេ[82]។

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្តល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង វត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ឬ ធ្វើការចាត់ចែងជាបណ្តោះអាសន្ន[83]។តុលាការ មានឆន្ទានុសិទ្ធិនៅក្នុងការជ្រើសរើសវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន។ក៏ប៉ុន្តែការសម្រេចរបស់តុលាការត្រូវស្របទៅតាមវិធានដូចខាងក្រោមនេះ៖

កម្រិត និង វិធិសាស្ត្រនៃការចាត់ចែងជាបណ្តោះអាសន្ន ត្រូវស្ថិតនៅក្នុង ទំហំនៃពាក្យសុំរបស់ម្ចាស់បំណុល ឬ អាចអនុវត្តបានចំពោះ កូនបំណុល ដោយការទាមទារផ្នែកអង្គសេចក្តី សិទ្ធិទាមទារនោះ គួរតែត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន ហើយដោយហេតុនេះគេមិនអាចដាក់ពាក្យសុំឱ្យចាត់ចែងជាបណ្តោះអាសន្នបានទេ។ម្យ៉ាងទៀតតុលាការអាចបង្គាប់ឱ្យកម្រិតក្នុងការធ្វើសកម្មភាព ឬ បង្គាប់ឱ្យផ្តល់តាវកាលិក ចំពោះតែកូនបំណុលតតិយជនផ្សេងទៀត ដែលត្រូវទទួលបានអនុភាពអនុវត្តដែលទាក់ទងនឹងសិទ្ធិទាមទារផ្នែកអង្គសេចក្តីប៉ុណ្ណោះ ពោលគឺមិនអាចធ្វើការចាត់ចែងណាដែលជះឥទ្ធិពលដោយផ្ទាល់ទៅដល់សិទ្ធិ និង ឋានៈគតិយុត្តរបស់តតិយជនផ្សេងទៀតបានឡើយ។ ក៏ប៉ុន្តែក្នុងករណីដែលតតិយជនត្រូវបានតម្រូវឱ្យទទួលស្គាល់ឋានៈរបសស់កូនបំណុល ដែលត្រូវចងដោយការ ចាត់ចែងជាបណ្តោះអាសន្ន តតិយជននោះអាចនឹងទទួលរងនូវឥទ្ធិពលពីការចាត់ចែងនោះ។ករណីបែបនេះ កើតមានច្រើននៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។

**ឧទាហរណ៍ ៖** បើមានការចាត់ចែងជាបណ្តោះអាសន្នដែលជ្រើសរើសដោយតុលាការ ត្រូវស្ថិតនៅទំហំដែលចាំបាច់ ដើម្បីសម្រេចនូវគោលបំណង នៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។ជាពិសេស នៅក្នុងការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ការចាត់ចែងមួយចំនួនដូចជាការផ្តល់ទៅអោយម្ចាស់បំណុល នូវការសម្រេចសិទ្ធិ ដូចគ្នានឹងការសម្រេចសិទ្ធិនៅក្នុងការអនុវត្តដោយបង្ខំដែរ នោះគឺជាការហួសពីគោលបំណងនៃការចាវចែងរក្សាការពារ។

---

[82] ជាការចាត់ចែងជាបណ្តោះអាសន្នដែលរំពឹងថាកូនបំណុលអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត។

[83] មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

វិធីសាស្រ្តជាក់លាក់នៃការចាត់ចែងជាបណ្តោះអាសន្នរួមមាន៖

១ .″ការចាត់ចែងអោយកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់″ គឺជាការបង្គាប់ឱ្យកូនបំណុលធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ។

**ឧទាហរណ៍ ៖** ការបង្គាប់ឱ្យរុះរើសំណង់ ការហាមឃាត់មិនអោយសាងសង់ ការហាមឃាត់មិនឱ្យធ្វើចរាចរណ៍ ការហាមឃាត់មិនឱ្យបោះពុម្ពផ្សាយជាសាធារណៈជាអាទិ៍។

២ . ″ ការចាត់ចែងឱ្យកូនបំណុលផ្តល់តាវកាលិក″ សំដៅទៅលើការបង្គាប់ឱ្យធ្វើសកម្មភាពដែលអាចអនុវត្តដោយផ្ទាល់បាន ដូចជាការប្រគល់វត្ថុ ការបណ្តេញចេញពីអចលនវត្ថុ និង ការសងជាប្រាក់ជាដើម។

៣ .″ការចាត់ចែងឱ្យថែរក្សាគ្រប់គ្រង ដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន″ មានន័យថា ជាការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវត្ថុនៃវិវាទ ពីកូនបំណុល ទៅឱ្យអ្នកថែរក្សាគ្រប់គ្រង។វិធីនេះត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីថែរក្សានូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មសិទ្ធិនៃវិវាទ។ជាទូទៅ អាជ្ញាសាលា ត្រូវបានចាត់ឱ្យធ្វើជាអ្នកថែរក្សាគ្រប់គ្រង។ក៏ប៉ុន្តែ ម្ចាស់បំណុល ឬ តតិយជនក៏អាចធ្វើជាអ្នកដៃរក្សាគ្រប់គ្រងបានដែរ។ក្នុងករណីដែលបានចាត់អាជ្ញាសាលា ឱ្យធ្វើជាអ្នកថែរក្សាគ្រប់គ្រងតុលាការក៏អាចធ្វើការចាត់ចែងជាបណ្តោះអាសន្ន ដែលអនុញ្ញាតឱ្យកូនបំណុលអាចប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនោះបានដែរ។

៤. ការចាត់ចែងចាំបាច់ផ្សេងទៀត មានដូចជា ការហាមឃាត់មិនឱ្យកូនបំណុលទី៣ សងនៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការប្រមូលបំណុល ការបង្គាប់ឱ្យប្រកាសជាសាធារណៈអំពីការណ៍ដែលអាជ្ញាសាលាកំពុងថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុ នៃវិវាទដោយអាជ្ញាសាលា នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យអាជ្ញាសាលាធ្វើជាអ្នកថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទជាដើម។

# ជំពូកទី៣
# ឧបាស្រ័យលើដីកាសម្រេចរក្សាការពារ

ជាទូទៅ បន្ទាប់ពីទទួលបានការសម្រេចសេក្តីនៅតុលាកាជាន់ទាបរួចមក តែងមានភាគីណាមួយកើតទុកមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលក្រម ឬសេចក្តីសម្រេចនោះ ទើបគេបើកផ្លូវឱ្យមាននូវបណ្តឹងឧបាស្រ័យ ដែលធ្វើឡើងនៅតុលាការជាន់ខ្ពស់។ នៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារនេះក៏ដូចគ្នាទៅនៅនឹងសំណុំរឿង ដ៏ទៃទៀតផងដែរ កាលណាភាគីម្ចាស់បំណុល ឬភាគីកូនបំណុលកើតទុក មិនសុខចិត្តនឹងដីកាសម្រេចរក្សាការពារ ភាគីនោះអាចធ្វើការប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់តុលាការ ដោយមធ្យោបាយណា

មួយដែលច្បាប់បានកំណត់។

## ផ្នែកទី១៖ ការតវ៉ាដីកាសម្រេចរក្សាការពារ

ចំពោះដីកាសម្រេចសរក្សាការពារមិនអាចធ្វើការប្ដឹងជំទាស់បានភ្លាមៗនោះទេ ប៉ុន្តែចំពោះការមិនសុខចិត្តនឹងដីកាសម្រេចនោះ យើងអាចធ្វើឧបាស្រ័យលើដីកាសម្រេចរក្សាការពារនោះទៅតុលាការដែលបានចេញដីកាសម្រេចនោះ។ របៀបនៃឧបាស្រ័យលើដីកាអាចធ្វើការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ អនុលោមទៅតាម ផ្នែកទី៤ ស្ដីពី ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងការលុបចោលចំពោះដីកាសម្រេចរក្សាការពារ អនុលោមតាម ផ្នែកទី៥ ស្ដីពីការលុបចោលដីកាសម្រេចរក្សាការពារ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីនេះ ជាឱកាសដែលអាចឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមនីតិវិធីជាមុន ក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃដីកាសម្រេច។ ជាទូទៅ តុលាការធ្វើការចេញដីកាសម្រេចរក្សាការពារ ដោយផ្អែកលើពាក្យសុំ និងសេចក្ដីបញ្ជាក់ដំបូងរបស់អ្នកដាក់ពាក្យសុំប៉ុណ្ណោះ នោះនាំឱ្យកូនបំណុលមិនអាចធ្វើការឆ្លើយតបបាន ដូចនេះទើបច្បាប់អនុញ្ញាតឱ្យកូនបំណុលអាចធ្វើការតវ៉ាដីកាសម្រេចរក្សាការពារបាន។

ហេតុនេះ បន្ទាប់ពីតុលាការចេញដីកាសម្រេចរក្សាការពារ កូនបំណុលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចចំពោះដីកាសម្រេចរក្សាការពារ អាចធ្វើការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេច[84] ឬសុំលុបចោលដីកាសម្រេចរក្សាការពារ[85] ទៅតុលាការដែលចេញដីកាសម្រេចនោះ។

### ១ .នីតិវិធីនៃការតវ៉ាដីកាសម្រេច

#### ក. ការដាក់ពាក្យសុំតវ៉ា

បន្ទាប់ពីភាគី ទទួលបានការបញ្ជូនដីកាសម្រេចរក្សាការពារពីតុលាការ[86] បើយល់ឃើញថាដីកាសម្រេចរក្សារការពារដែលចេញមកនោះ មិនស្របតាមលក្ខខណ្ឌនៃច្បាប់តម្រូវទេ កូនបំណុលអាចសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារនោះបានតាមរយៈការដាក់ពាក្យសុំនៃភាគី។ ភាគីអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនោះបាន ទៅតុលាការដែលបានចេញដីកាសម្រេចនោះផ្ទាល់។ ពាក្យសុំត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដាច់ខាត[87] ដើម្បីធានាភាពច្បាស់លាស់។ ចំពោះរយៈពេលនៃការតវ៉ាចំពោះដីកាសម្រេច មិនបានកំណត់អំឡុងពេលដាក់លាក់ណាមួយឡើយ ហេតុនេះយើងអាច

[84] មាត្រា ៥៥០ ក្រមនីតិវិធិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[85] មាត្រា ៥៥៧ ដល់មាត្រា ៥៥៩ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណចាក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[86] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[87] មាត្រា ៥៣៤ ចំណុច គ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

ដាក់ពាក្យសុំបាន ឱ្យតែដីការក្សាការពារនោះនៅមានសុពលភាព។

**ខ. ការទាញហេតុផលផ្ទាល់មាត់**

បន្ទាប់ពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានដាក់រួចរាល់ហើយ ចៅក្រមដែលបានចេញដីកាសម្រេចនោះ ត្រូវធ្វើការកោះហៅភាគី និងធ្វើការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរក្សាការពារ តុលាការមិនអាចធ្វើការសម្រេចណាមួយដោយមិនបានឆ្លងកាត់នូវដំណាក់កាលសាកសួរភាគី ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ឡើយ[88]។ ក្រោយពីនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចចេញសេចក្តីសម្រេចណាមួយបាន ហើយនៅក្នុងនីតិវិធីនៃការទាញហេតុផលនេះជាសេចក្តីបញ្ជាក់ អំពីការបង្ហាញរបស់ភាគីនៅចំពោះមុខតុលាការ។

**គ. ដីកាសម្រេចការសុំតវ៉ាលើដីកាសម្រេចរក្សាការពារ**

ក្នុងការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេច តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬធ្វើការសាកសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[89]។ នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យដើម្បីឱ្យភាគីមានឱកាសផ្តល់សំអាងបន្ថែមទៀត សម្រាប់ការពារផលប្រយោជន៍របស់ខ្លួន។ ប៉ុន្តែ តុលាការអាចធ្វើការប្រកាសភ្លាមបាន អំពីការបញ្ចប់ការវិនិច្ឆ័យនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន[90]។

ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលនូវដីកាសម្រេចរក្សាការពារ[91] ។ មានន័យថា ចំពោះដីកាសម្រេចរក្សាការពារចាស់(ដីកាសម្រេចរក្សាការពារដែលធ្វើពីមុន) ក្នុងករណីដែលយល់ឃើញថាត្រឹមត្រូវ នោះតុលាការត្រូវទទួលស្គាល់ដីកានោះ តែបើមានចំណុចដែលត្រូវកែតម្រូវ ត្រូវធ្វើការផ្លាស់ប្តូរ ហើយបើសិនជាយល់ឃើញថាមិនត្រឹមត្រូវទេ តុលាការត្រូវលុប ចោល។ ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ដែលធ្វើឡើងតាមការពិចារណារបស់តុលាការ នោះតុលាការអាចដាក់ល័ក្ខខណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន[92] ។ ចំពោះដីកាសម្រេចការតវ៉ាចំពោះដីកា

[88] មាត្រា ៥៥២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[89] មាត្រា ៥៥២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[90] មាត្រា ៥៥៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[91] មាត្រា ៥៥៤ កថាខ័ណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[92] មាត្រា ៥៥៤ កថាខ័ណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

សម្រេចរក្សាការពារ តុលាការត្រូវបញ្ជូនទៅភាគី[93]ដូចកាលចេញដីកាសម្រេចរក្សាការពារមុនដែល។

## ២ .ការលុបចោលដីកាសម្រេច

### ក. មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ

ក្នុងករណីដែលដីកាសម្រេចរក្សាការពារត្រូវបានចេញ ហើយមានមូលហេតុមួយចំនួនត្រូវបានកំណត់ដូចមានក្នុង មាត្រា ៥៥៧ ដល់មាត្រា ៥៥៩នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះភាគី ឬកូនបំណុលអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារនោះបាន។ ដូចនេះមូលហេតុនៃការសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ រួមមាន៖ ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍[94] ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព[95] ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស[96]។

- ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍៖
  តុលាការ ដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹង អង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។[97] ការបង្គាប់នេះហៅថា **ការបង្គាប់ឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី**។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំឱ្យម្ចាស់បំណុលទទួលលិខិតអនុវត្តសម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះ នឹងទប់ស្កាត់ការ ខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាពដែលមានដីកាសម្រេចរក្សាការពារឱ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឱ្យដាក់ពាក្យបណ្តឹង អាចចេញបានដោយមិនតម្រូវឱ្យមានលក្ខខណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនៃការដាក់ពាក្យបណ្តឹងអង្គសេចក្តីត្រូវមានរយៈពេលតិចជាង ២ (ពីរ) សប្តាហ៍។[98] ប្រសិនបើម្ចាស់បំណុលមិនបានធ្វើការដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការដាក់ពាក្យបណ្តឹងអង្គសេចក្តីនោះទេ នៅអំឡុងពេលដែលបានកំណត់ក្នុងការបង្គាប់ឱ្យដាក់ពាក្យបណ្តឹង

[93] មាត្រា ៥៥៤ កថាខ័ណ្ឌទី ៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦
[94] មាត្រា ៥៥៧ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦
[95] មាត្រា ៥៥៨ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦
[96] មាត្រា ៥៥៩ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦
[97] មាត្រា ៥៥៧ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦
[98] មាត្រា ៥៥៧ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

នោះតុលាការត្រូវលុបចោល ដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល។[99] ក្នុងករណីដែល ក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នោះត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ហើយក៏នាំឱ្យចេញដីកាសម្រេចលុបចោលផងដែរ។[100]

❖ ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្ដូរស្ថានភាព៖ បើមានការរលត់សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។[101] ចំពោះការផ្លាស់ប្ដូរស្ថានភាពនេះត្រូវបានគេបែងចែកចេញជា ២ (ពីរ) ប្រភេទ ។ ប្រភេទទី១ បន្ទាប់ពីចេញដីកាសម្រេចរក្សាការពារ កើតមានឡើងនូវអង្គហេតុថ្មី ដែលអង្គហេតុនោះបានបញ្ជាក់អំពីភាពមិនត្រឹមត្រូវនៃដីកាសម្រេច។ ប្រភេទី២ សំដៅកូនបំណុលបានដឹងអំពីអង្គហេតុដែលឆ្លុះបញ្ចាំងអំពីភាពមិនត្រឹមត្រូវនៃដីកាសម្រេចនោះ ឬអាចធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីអង្គហេតុ នៅក្រោយពេលចេញដីកាសម្រេច ទោះបីជាអង្គហេតុនោះបានកើតឡើងនៅកំឡុងពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ។ ដូចច្នេះ កូនបំណុល ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង អំពីការផ្លាស់ប្ដូរស្ថានភាព។[102]

❖ ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេស៖ ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬមានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវ ឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។[103] ករណីដែលអាចលុបចោលដីកាសម្រេចរក្សាការពារ ដោយមានស្ថានភាពពិសេសមានករណីធំ ២(ពីរ) ។ ករណីទី ១ គឺ ស្ថានភាពដែលអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្ន ដោយការសងជាទឹកប្រាក់ទៅម្ចាស់បំណុល។ ករណីទី២ គឺ ករណីដែលកូន

[99] មាត្រា ៥៥៧ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[100] មាត្រា ៥៥៧ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[101] មាត្រា ៥៥៦ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[102] មាត្រា ៥៥៦ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[103] មាត្រា ៥៥៩ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

បំណុលទទួលការខូចខាតមិនធម្មតាហួសហេតុ តាមទស្សនៈនៃសមភាពរវាងភាគីទាំង សងខាង ។[104] កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ចំពោះករណីស្ថានភាពពិសេសដូចមានកំណត់ខាងលើ។

គ្រប់បទប្បញ្ញត្តិនៃមូលហេតុដែលនាំឱ្យមាន ការលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានយកមកអនុវត្តដូចគ្នានៃបញ្ញត្តិមាត្រា ៥៤៣ ស្តីពី ការបញ្ជូន របស់តុលាការចំពោះដីកាសម្រេចការពារ ក្នុងគោលបំណងឱ្យភាគីបានដឹងច្បាស់អំពីខ្លឹមសារនៃដីកាសម្រេច និងបន្សល់ឱ្យភាគីនូវមធ្យោបាយបញ្ជាក់។

**ខ. ការទាញហេតុផលផ្ទាល់មាត់**

នីតិវិធីនៃសំណុំរឿងរក្សាការពារ ក្នុងសំណុំរឿងរដ្ឋប្បវេណី តុលាការមិនអាចចេញដីកាសម្រេចណាមួយបានឡើយ បើមិនបានឆ្លងកាត់នូវនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីម្ចាស់បំណុល និងភាគីកូនបំណុលអាចចូលរួមបាន។ ដូចនេះនៅក្នុងផ្នែកនៃការលុបចោលដីកាសម្រេចរក្សាការពារ ត្រូវយកមកអនុវត្តដូចគ្នាផងដែល ចំពោះ បញ្ញត្តិមាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**គ. ផ្អាកបណ្តោះអាសន្ន**

បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ ( ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ ( អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តី អំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌ ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍) ។[105] ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្ត រក្សាការពារ ជាអាទិ៍) នៃនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវយកមកអនុវត្តដូចគ្នា ក្នុងករណីដែល ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្តឹងអង្គសេចក្តីផ្សេងពីតុលាការដែលបាន ចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែល បានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។[106]

---

[104] ទំព័រទី ៥៤៨ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧

[105] មាត្រា ៥៦០ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

[106] មាត្រា ៥៦០ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

ជារួម នៅពេលដែលមានពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ ឱ្យផ្អាកលើការអនុវត្ត ឬលុបចោលនូវការចាត់ចែងការអនុវត្តតាមពាក្យសុំ ដោយភ្ជាប់ជាមួយនឹងការដាក់ប្រាតិភោគ បានរហូតដល់ធ្វើការសម្រេច អំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារក្នុងស្ថានភាពពិចារណា ថាតុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬទទួលស្គាល់នូវសេចក្តីសម្រេចជាមុនសិន។ មានន័យថា ការអនុវត្តការរក្សាការពារ មិនអាចផ្អាកបានឡើយ បើត្រឹមតែធ្វើការតវ៉ាចំពោះដីកាសម្រេចរក្សាការពារនោះ ស្ថានភាពដែលច្បាស់ថាជាមូលហេតុ នៃការលុបចោលដីកាសម្រេចរក្សាការពារ និងការដែលបារម្ភថា មានការខូចខាតដែលមិនអាចធ្វើការសងបាន នឹងកើតឡើងដោយការអនុវត្តរក្សាការពារ ហើយចាំបាច់ត្រូវដាក់ប្រាតិភោគ ទើបអាចធ្វើការផ្អាកការអនុវត្តរក្សាការពារបាន ដោយការតវ៉ាចំពោះដីកាសម្រេច ដែលត្រូវបំពេញល័ក្ខខ័ណ្ឌខាងលើនេះ។

**ឃ. អានុភាពនៃដីកាដែលសម្រេចលុបចោលដីកាសម្រេច**

ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ និងដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ មិនមានអានុភាពឡើង ក្នុងករណីដែលមិនទាន់ចូលជាស្ថាពរ។ ប៉ុន្តែបើយល់ឃើញថាចាំបាច់ ករណីពិសេសតុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ។ ជាគោលការណ៍ ដីកាសម្រេចមានអានុភាព នៅពេលជូនដំណឹង[107]។ ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ មានន័យថា ដីកាសម្រេចរក្សាការពារ នៅតែមាន អានុភាពដដែល។

## ៣.ការអនុវត្ត

ចំពោះការចាត់ចែងរក្សាការពាររបស់តុលាការអនុវត្តដែលមិនអាចប្តឹងជំទាស់បាន អាចតវ៉ា ទៅតុលាការអនុវត្តបាន[108]។នៅក្នុងករណីដែលការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និងការយឺតយ៉ាវ និងការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្តនោះ អាចតវ៉ាទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅបាន[109]។មូលហេតុនៃការតវ៉ាសម្រាប់ការអនុវត្ត ដោយសារនីតិវិធីនៃការអនុវត្តផ្ទុយនឹងច្បាប់។

ឧទាហរណ៍ ការរឹបអូសជាតួនាទីរបស់អាជ្ញាសាលា[110]តែភាគីត្រូវបានគេបង្ខំឱ្យអនុវត្តខ្លួនឯង នាំអោយ

---

107 មាត្រា ២១៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ០៦ កក្កដា ២០០៦

108 មាត្រា៣៨៤ កថាខណ្ឌទី១ នៃក្រមនីតិរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

109 មាត្រា៣៨៤ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

110 មាត្រា៣៨៥ កថាខណ្ឌទី១ នៃក្រមនីតិរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

ការអនុវត្តនោះផ្ទុយនឹងច្បាប់។

**ក. បុគ្គលដែលមានទំនាក់ទំនងគតិយុត្ត**

បុគ្គលដែលអាចធ្វើការតវ៉ាចំពោះការអនុវត្តនេះបាន គឺបុគ្គលគ្រប់រូបដែលមានការប៉ះពាល់ដោយសារការអនុវត្ត ឬបុគ្គលដែលមានផលប្រយោជន៍ពាកព័ន្ធនឹងការអនុវត្ត។

បុគ្គលទាំងនោះរួមមាន៖

- **ម្ចាស់បំណុលនៃការអនុវត្ត** : បើការអនុវត្តនោះនាំឱ្យខូចប្រយោជន៍របស់ម្ចាស់បំណុលនៃ ការអនុវត្ត ក៏អាចតវ៉ាចំពោះការអនុវត្តនោះបានដែរ។ ឧទាហរណ៍ ពេលចូលទៅអនុវត្ត អាជ្ញាសាលាមិនព្រមកាន់កាប់វត្ថុ ទោះបីជាគ្មានការតវ៉ាពីជនណាក៏ដោយ។
- **កូនបំណុលនៃការអនុវត្ត** : បើការអនុវត្តនាំអោយខូចប្រយោជន៍របស់កូនបំណុល កូនបំណុលនៃការអនុវត្ត ក៏អាចតវ៉ាចំពោះការអនុវត្តបានដែរ។
- **តតិយជន** : បើតតិយជននាំឱ្យខូចប្រយោជន៍តតិយជន តតិយជនក៏អាចតវ៉ាចំពោះការអនុវត្តបានដែរ។

ក្នុងការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេង ក្រៅពីកូនបំណុលនៃការអនុវត្ត បើតតិយជនមិនបដិសេធចំពោះការអនុវត្តនោះអាជ្ញាសាលាអាចអនុវត្តបាន[111]។ប៉ុន្តែបើតតិយជនតវ៉ាចំពោះការអនុវត្ត តែអាជ្ញាសាលាមិនព្រមបញ្ឈប់ការអនុវត្ត នាំអោយការអនុវត្តនោះផ្ទុយនឹងច្បាប់ ដូច្នេះតតិយជនអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការអនុវត្តបាន។

**ខ. សមត្ថកិច្ច/អាជ្ញាធរ**

ការតវ៉ាចំពោះការអនុវត្តអាចដាក់បាន នៅពេលការអនុវត្តកំពុងត្រូវបានអនុវត្ត។ប៉ុន្តែបើការអនុវត្តបានអនុវត្តចប់សព្វគ្រប់ហើយនោះ ការតវ៉ាចំពោះការអនុវត្តបែបនេះមិនអាចដាក់បានទេដោយសារថា ផលប្រយោជន៍នៃការតវ៉ានោះបានបាត់បង់។ពាក្យសុំតវ៉ាត្រូវដាក់ក្នុងតុលាការអនុវត្ត ឬ អាជ្ញាសាលាអាស្រ័យទៅលើការអនុវត្តនោះ ដោយអាជ្ញាសាលា ឬ ក៏តុលាការអនុវត្ត។ការតវ៉ាត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥០០០ (ប្រាំពាន់) រៀល [112]ទៅសាលាដំបូងដែលមានមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតក្រោម។

**គ. ផ្អាកបណ្តោះអាសន្ន**

អនុភាពនៃការចាត់ចែងការអនុវត្ត ឬ នីតិវិធីនៃការអនុវត្ត មិនត្រូវបានផ្អាកដោយស្វ័យប្រវត្តិនោះទេ នៅពេលដែលធ្វើការអនុវត្តចំពោះការអនុវត្ត ព្រោះវាអាចបណ្តាលអោយមានការខូចខាតដែលមិនអាចជួសជុល

---

[111] មាត្រា៣៨៦ នៃក្រមនីតិរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

[112] ប្រកាស ១៣ នៃប្រកាសលេខ ៣០ កយប្រក ០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ២០០៧

បាន ចំពោះបុគ្គលដែលបានធ្វើការតវ៉ាចំពោះការអនុវត្ត ករណីបើសិនជាការអនុវត្តមិនត្រូវបានផ្អាកការអនុវត្តគ្រប់ករណីនោះ។ដូច្នេះដើម្បីបញ្ចៀសនូវការលំបាកនេះតុលាការអាចបង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តមួយផ្នែក ឬ ទាំងមូល ដោយដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ។ដីកាសម្រេចផ្អាកដែលតុលាការនៃបណ្តឹងជំទាស់អាចធ្វើបានមានពីរ[113]គឺ

១ ដីកាសម្រេចផ្អាកអនុភាពនៃដីកាសម្រេចដើម

២ ដីកាសម្រេចផ្អាកមួយផ្នែក ឬ ទាំងមូលដោយដាក់ប្រាតិភោគ ឬ មិនអោយដាក់ប្រាតិភោគ។

**ឃ. ដីកាសម្រេច**

ដីការសម្រេចអំពីការតវ៉ាចំពោះការអនុវត្តដែលធ្វើឡើងដោយតុលាការអនុវត្ត គឺជាដីកាសម្រេចលើកចោលពាក្យសុំ ឬ ដីកាសម្រេចទទួលស្គាល់ពាក្យសុំ។ក្នុងករណីដែលតុលាការសម្រេចថា ការចាត់ចែងការអនុវត្តដើមមានលក្ខណៈត្រឹមត្រូវ តុលាការត្រូវលើកចោលនូវពាក្យសុំតវ៉ា។ប៉ុន្តែបើតុលាការយល់ឃើញថាការចាត់ចែងការអនុវត្តដើមមានលក្ខណៈមិនត្រឹមត្រូវ៖

១- តុលាការត្រូវលុបចោលនូវការចាត់ចែងដើម នៅក្នុងករណីដែលមានការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត។

២- តុលាការត្រូវចេញដីកាបង្គាប់ឱ្យអជ្ញាសាលាលុបចោលនូវការចាត់ចែងការអនុវត្តដើម ឬ តុលាការត្រូវចេញដីកាសម្រេចដែលមានខ្លឹមសារថា ការអនុវត្តដោយបង្ខំមិនត្រូវបានអនុញ្ញាតនៅក្នុងករណីដែលមានការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា។

ចំណែកឯដីកាសម្រេចអំពីការតវ៉ាចំពោះការអនុវត្តដែលដែលធ្វើឡើងដោយអាជ្ញាសាលានោះជាគោលការណ៍ ដីការសម្រេចនេះគឺមានគោលដៅបង្គាប់អោយអាជ្ញាសាលាលុបចោលនូវការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា។

## ៤.បណ្តឹងជំទាស់

បណ្តឹងជំទាស់គឺជានីតិវិធីមួយដែលផ្តល់ឱកាសអោយភាគី ដែលមិនសុខចិត្តនឹងដីកាសម្រេចរបស់តុលាការ។នៅពេលមានបណ្តឹងជំទាស់ តុលាការអាចបង្គាប់អោយផ្អាក់ការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបានរហូតដល់តុលារការសម្រេចសេចក្តីថា ត្រូវលុបចោលផ្លាស់ប្តូរ ឬ លុបចោល ឬ ទទួលស្គាល់នូវដីកាសម្រេចដែលបាននធ្វើរួចហើយ។ បណ្តឹងជំទាស់អាចធ្វើបានចំពោះដីការសម្រេចមានដូចជា៖

- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទាអោយលុប

[113] មាត្រា៣៨៤ កថាខណ្ឌទី៣ មាត្រា៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

ចោលដីការសម្រេចរក្សាការពារ

- ❖ ដីកាសម្រេចដែលទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលដីកាសម្រេចរក្សាការពារដោយផ្អែកលើពាក្យសុំតវ៉ា និង
- ❖ ដីកាសម្រេចដែលលើកចោលពាក្យសុំទាមទារឱ្យលុបចោល ឬ
- ❖ ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ដោយផ្អែកលើពាក្យសុំទាមទាអោយលុបចោលដីកាសម្រេចទាំងនេះសុទ្ធតែអាចប្តឹងជំទាស់បាន។

បញ្ញត្តិទាក់ទងនិងការសម្រេចសេចក្តី និងដីកាសម្រេច នៅតុលាការនៃជំនុំជម្រះអំពីការតវ៉ាយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសេចក្តីសម្រេច និងដីការសម្រេចនៅតុលាការនៃបណ្តឹងជំទាស់[114]។អំឡុងពេលនៃការប្តឹងជំទាស់ គឺ រយៈពេល២ (ពីរ)សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន[115]។

**ក. ការទាញហេតុផលផ្ទាល់មាត់**

នៅក្នុងនីតិវិធីនៃការសម្រេចសេចក្តីចំពោះបណ្តឹងជំទាស់ តុលាការនៃបណ្តឹងជំទាស់ត្រូវសម្រេចសេចក្តីដោយឆ្លងកាត់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។

**ខ. ដីកាសម្រេច**

បន្ទាប់ពីបញ្ចាប់ការវិនិច្ឆ័យដោយការទាញតុផលដោយផ្ទាល់មាត់ ឬការបរិច្ឆេទនៃការសួរដែលភាគីដែលទាំងសងខាងអាចចូលរួមបានរួចមក កិច្ចបន្ទាប់ជាដំណាក់កាលដែលតុលារការត្រូវធ្វើការសម្រេចសេចក្តីទៅលើបណ្តឹងជំទាស់នោះ។

១ .បណ្តឹងជំទាស់ចំពោះដីការសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារមាន២គឺៈ

បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចដើម សេចក្តីសម្រេចលើបណ្តឹងជំទាស់មានពីរ ករណីគឺតុលាការនៃបណ្តឹងជំទាស់អាចនឹងៈ

- ❖ ចេញដីកាសម្រេចរក្សាទុកដីកាសម្រេចដើម (មិនអាចប្តឹងជំទាស់បានទៀតទេ)[116]ឬ
- ❖ ចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម មានន័យថាចេញដីកាសម្រេចរក្សាការពារ(ដីកាសម្រេចរក្សាការពារអាចដាក់ពាក្យសុំតវ៉ាបាន)[117]។

បណ្តឹងជំទាស់ចំពោះដីកាសម្រេចទទួលស្គាល់ដីកាសម្រេចដើម សេចក្តីសម្រេចមាន ពីរ ករណី ដូច

[114] មាត្រា៥៦១ កថាខណ្ឌទី១ នៃក្រមនីតិរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ២០០៦

[115] មាត្រា៥៦១ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

[116] មាត្រា២៥៩ កថាខណ្ឌទី៣ នៃក្រមនីតិរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ២០០៦

[117] មាត្រា២៥៩ កថាខណ្ឌទី៣ នៃក្រមនីតិរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ២០០៦

ខាងលើដែរ គឺ អាចនឹងត្រូវបានតុលាការនៃបណ្តឹងជំទាស់៖

- ចេញដីកាសម្រេចរក្សាទុកដីកាសម្រេចដើម (មិនអាចប្តឹងជំទាស់ទៀតបានទេ)ឬ
- ចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម(មិនអាចប្តឹងជំទាស់ទៀតបានទេ)។

២ .ចំណែកឯសេចក្តីសម្រេចអំពីបណ្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យដីកាសម្រេចរក្សាការពារ គឺ អាចនឹងត្រូវតុលាការនៃបណ្តឹងជំទាស់[118]៖

- ចេញដីកាសម្រេចរក្សាទុកដីកាសម្រេចដើម ឬ
- ចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម(ចេញដីកាសម្រេចរក្សាការពារ)។

បន្ទាប់ពីតុលាការបានសម្រេចសេចក្តីអំពីបណ្តឹងជំទាស់រួចមក តុលាការត្រូវបញ្ជូនដីកាសម្រេចនោះទៅភាគី។

[118] មាត្រា ៥៤៤ នៃក្រមនីតិរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ៦ កក្កដា ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវលើប្រធានបទ "**នីតិវិធីនៃការចាត់ចែងរក្សាការពារ ក្នុងសំណុំរឿងរដ្ឋប្បវេណី**" ក្រុមរបស់យើងខ្ញុំយល់ឃើញថា នីតិវិធីនៃការចាត់ចែងរក្សាការពារ ជានីតិវិធីបន្ទាប់បន្សំទៅនឹងនីតិវិធីនៃបណ្តឹងអង្គសេចក្តី ហើយបានជួយបំពេញបន្ថែមដល់នីតិវិធីនៃការអនុវត្តដោយបង្ខំ។ ហេតុដូចនេះ ទើបនីតិវិធីនៃការចាត់ចែងរក្សាការពារមានការអនុវត្តច្បាប់ស្រដៀងច្រើន ជាមួយនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំ។ លើសពីនេះ វាជាដំណាក់កាលនៃនីតិវិធីបណ្តឹងអង្គសេចក្តី ដែលជួយការពារ ការខូចផលប្រយោជន៍នៅក្នុងរយៈពេលនៃបណ្តឹង ចំពោះម្ចាស់បំណុល និងកូនបំណុល។ ហើយការចាត់ចែងរក្សាការពារនេះផងដែរក៏មានទាំងគុណសម្បត្តិ និងគុណវិបត្តិផងដែរ នៅកំឡុងពេលចាប់ផ្តើមនីតិវិធីចាត់ចែងរក្សាការពារនេះ។ចំពោះគុណសម្បត្តិនៃការចាត់ចែងរក្សាការពារមានសារៈសំខាន់ត្រង់ថា ការចាត់ចែងរក្សាការពារ គឺជាយន្តការបណ្តោះអាសន្នម្យ៉ាងដែលអាចទប់ស្កាត់នូវភាពលំបាកដែលអាចនឹងកើតមានឡើងចំពោះភាគី ដែលមានការព្រួយបារម្ភថាខ្លួននឹងមិនអាចអនុវត្តសិទ្ធិ រហូតដល់ការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកានៃបណ្តឹងអង្គសេចក្តី។ ជាក់ស្តែងវិធានការរក្សាការពារ បានធានានូវស្ថានភាពដើមនៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តមិនឱ្យធ្វើការ

ចាត់ចែងចំពោះវត្ថុនៃវិវាទដែលបានដាក់រក្សាការពារ ក្នុងគោលបំណងនៃការទាមទារឱ្យសងជាទឹកប្រាក់របស់ម្ចាស់បំណុលនាពេលអនាគត។ ស្ថេរភាពសេដ្ឋកិច្ច ត្រូវបានធានាផងដែរចំពោះម្ចាស់បំណុល ដែលមានការកំណត់បាននូវឋានៈជាបណ្តោះអាសន្នក្នុងពេលមានទំនាស់ដែលទាក់ទិននឹងសិទ្ធិ ហើយមិនធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរចំពោះគូភាគី ឬស្ថានភាពគ្រោះថ្នាក់ជាបន្ទាន់ណាមួយ។ មិនត្រឹមតែប៉ុណ្ណោះ ការចាត់ចែងរក្សាការពារធានាបាននូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ មិនឱ្យមានការប្រែប្រួលខុសស្ថានភាពដើមដោយសារការចាត់ចែងរបស់កូនបំណុល។

ចំណែកឯគុណវិបត្តិនៃការចាត់ចែងរក្សាការពារក៏មានមួយចំនួនផងដែរ។ នៅពេលដែលពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ បានដាក់ទៅតុលាការត្រូវធ្វើការសម្រេចសេចក្តីលើពាក្យសុំនោះទេ។ដោយសារថាកំណត់របស់ច្បាប់មានភាពទូលាយពេកនេះហើយ វាជាហេតុដែលភាគីដែលដាក់ពាក្យសុំទទួលរងការខូចខាតធ្ងន់ធ្ងរដោយសារសេចក្តីសម្រេចមានភាពយឺតយ៉ាវ។ ហេតុនេះហើយទោះបីជាដីកាសម្រេចរក្សាការពារបានចេញហើយក៏ដោយ ប្រសិនបើកម្មវត្ថុដែលត្រូវរក្សាការពារបានប្រែប្រួល ឬ បានផ្ទេរទៅឱ្យតតិយជនបាត់ទៅហើយ ឬ អំឡុងពេលដែលឋានៈជាបណ្តោះអាសន្នរបស់ភាគីមិនត្រូវបានកំណត់ទាន់ពេលវេលាទេ ដីការ

សម្រេចរក្សាការពារនេះ លែងឆ្លើយតបទៅនឹងភាពចាំបាច់នៃការរក្សាការពារទៀតហើយ។ បញ្ហាមួយទៀត នៅពេលដែលអនុវត្តការចាត់ចែងរក្សាការពារ អាចបណ្តាលអោយមានការខូចខាតដោយសារអានុភាពនៃការផ្អាក ឬ ហាមឃាត់របស់ដីការសម្រេចរក្សាការពារផងដែរ ព្រោះតែកំហុសមិនបានឱ្យភាគីធ្វើការដាក់ប្រាតិភោគចំពោះដីកាសម្រេចនោះ។មួយវិញទៀត ការចាត់ចែងរក្សាការពារ អាចនេងមានឧបសគ្គមួយចំនួនផងដែរ ដូចជាការតវ៉ាចំពោះដីកាសម្រេចរក្សាការពារបណ្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារជាអាទិ៍។លើសពីនេះទៅទៀត នៅពេលដែលអាជ្ញាសាលាចុះទៅអនុវត្ត គឺ ពិតជាមានការលំបាក ព្រោះថាអ្នកដែលកាន់កាប់នូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាត់ចែងរក្សាការពារ អាចនឹងធ្វើការតបតប្រឆាំងនឹងការអនុវត្តនោះ។ដូច្នេះ ដើម្បីធានាក្នុងការបំពេញតួនាទីរបស់ខ្លួនអាជ្ញាសាលា អាចប្រើកម្លាំង ឬ សុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន។

ភាគីម្ចាស់បំណុល និងកូនបំណុលអាចធ្វើការស្នើសុំរក្សាការពារបានដោយការដាក់ពាក្យសុំជាលាយលក្ខអក្សរ ដែលបានសរសេរបញ្ជាក់ច្បាស់លាស់អំពី អត្តសញ្ញាណ ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ សិទ្ធ ឬទំនាក់ទំនងគត្តិយុត្តដែលនឹងត្រូវបានរក្សាការពារ ភាពចាំបាច់នៃការរក្សាការពារ និងភស្តុតាង ទៅតុលាការដែលមានសមត្ថកិច្ចក្នុងការសម្រេច។ សេចក្តីសម្រេចនៃការចាត់ចែងរក្សាការពារ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ។

សរុបសេចក្តីមក ការចាត់ចែងរក្សាការពារបានផ្តល់នូវគុណសម្បត្តិជាច្រើនដល់ភាគីដែលកើតមាន

ឡើងនូវវិវាទ ហើយមានការបារម្ភថា ការអនុវត្តដោយបង្ខំមិនអាចធ្វើបាន ឬនឹងមានការលំបាកក្នុងការអនុវត្ត ដោយសារការប្រែប្រួលលក្ខណៈនៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬបារម្ភថានឹងមានការខូចខាត ធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ចំពោះឋានៈនៃភាគី ដោយសារទំនាស់នៃសិទ្ធិ នោះបុគ្គលដែលមានការបារម្ភថាខ្លួននឹង ត្រូវបាត់បង់សិទ្ធិទាំងនេះ អាចធ្វើការរក្សាការពារបានទៅតាមបទប្បញ្ញត្តិដែលច្បាប់បានកំណត់ជាធរមាន។ ទន្ទឹមនឹងនេះការចាត់ចែងរក្សាការពារក៏បានផ្តល់នូវផលវិបាកមួយចំនួនផងដែរអាស្រ័យថាភាគីដេលដែលនឹង រងការខូចខាតដែលកើតមានឡើង មានសិទ្ធិ ឬ មានទំនាក់ទំនងគតិយុត្តពិតប្រាកដជាមួយភាគីម្ខាងទៀតដែរឬ ទេ។ពេលខ្លះក៏មានជនទុច្ចរិតមួយចំនួន ចង់បង្កបញ្ហាអោយភាគីម្ខាងទៀតខាតបង់ពេលវេលាតែប៉ុណ្ណោះ។ដូច នេះនណោះមុនពេលតុលាការសម្រេចចេញដីកាសម្រេចរក្សាការពារត្រូវពិនិត្យទៅលើភស្តុតាង ដែលបានបញ្ជាក់ អំមពីការទាមទារនោះតែវាក៏ផ្តល់ផលប៉ះពាល់ខ្លះដែរដល់ភាគី នៅពេលដែលតុលាការសម្រេចចេញដីការក្សា ការពារនោះ។

# អនុសាសន៍

ជាការផ្តល់យោបល់បន្តិចបន្តួចពីក្រុមយើងខ្ញុំ បន្ទាប់ពីបានសិក្សាពីនីតិវិធីនៃការចាត់ចែងរក្សាការពារ នេះរយៈពេលកន្លងមក យល់ឃើញថានីតិវិធីចាត់ចែងរក្សាការពារនេះជានីតិវិធី បន្ទាប់បន្សំពីនីតិវិធីអង្គសេចក្តី។ ជាការយល់ឃើញរបស់ក្រុមយើងខ្ញុំផ្ទាល់យល់ឃើញថា ចំពោះបុគ្គលដែលមានវិវាទទៅលើសិទ្ធិ ឬទំនាក់ទំនង គតិយុត្តណាមួយ ខ្ញុំគិតថាម្ចាស់បំណុលគួរតែដាក់ពាក្យសុំចាត់ចែងរក្សាការពារមុនបណ្តឹងអង្គសេចក្តី ព្រោះអាច នឹងកូនបំណុលធ្វើការអនុវត្ត ដោយស្ម័គ្រចិត្តមុនការបញ្ចប់អង្គសេចក្តីផងដែរ។

មួយវិញទៀតយើងខ្ញុំយល់ឃើញថាទាក់ទងទៅនឹង នីតិវិធីនៃដំណើរការក្នុងរឿងក្តីរដ្ឋប្បវេណី សម្រាប់ ប្រជាជនមួយភាគធំ នៅមិនទាន់មានការយល់ច្បាស់អំពីនីតិវិធីនេះនៅឡើយបើទោះបីជាយើងមានក្រមរដ្ឋ ប្បវេណីដែលបានដាក់អោយប្រើជាយូរមកក៏ដោយ។ ហេតុនេះហើយយើងខ្ញុំសូមជូនអនុសាសន៍ដូចខាងក្រោះ

- ត្រូវបង្កើន នឹងពង្រីកការផ្សព្វផ្សាយអំពីប្រព័ន្ធច្បាប់អោយបនច្រើន អំពីនីតិវិធី ទាំងក្នុង រឿងក្តី រដ្ឋប្បវេណី និង ក្នុងរឿងក្តីព្រហ្មទណ្ឌ
- ជម្រុញនិងខិតខំបង្កើតឱ្យមានតុលាការឱ្យចំជំនាញរបស់ខ្លួន ដើម្បីអោយមានការទុកចិត្ត

ពីប្រជាពលរដ្ឋ

❖ សូមអង្គការ ឬ ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការធ្វើច្បាប់កំណត់ពីវិធានច្បាប់អោយបានជាក់លាក់ ដើម្បីជៀសវាងការសម្រេចសេចក្តីយឺតយ៉ាវរបស់ចៅក្រម។

មួយវិញទៀតចំពោះការអនុវត្តជាក់ស្តែង ការដាក់ពាក្យសុំរក្សារការពារតែងត្រូវបានតុលាការលើកចោលដោយមិនទាន់មានចាត់កម្មវិធីសាកសួរឡើយ។ ដោយហេតុថា ការសរសេរពាក្យសុំ មិនបានបញ្ជាក់អំពីមូលហេតុ ឬភាពចាំបាច់នៃការស្នើសុំរក្សាការពារ និងលម្អិតនៃកម្មវត្ថុដែលត្រូវសុំរក្សាការពារនោះទេ។ ហេតុដូចនេះមុននឹងធ្វើការសុំរក្សារការពារគួរសរសេរពាក្យសុំឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋានគតិយុត្តដែលមានចែងក្នុងបទប្បញ្ញត្តិនៃនីតិវិធីចាត់ចែងរក្សាការពារ។

ទាំងអស់នេះគ្រាន់ជាមតិរបស់ក្រុមយើងខ្ញុំតែប៉ុណ្ណោះ ប៉ុន្តែបើច្បាប់អាចកំណត់ដូចនេះបានយើងខ្ញុំគិតថាវាជាការល្អប្រសើរ។

# ឯកសារយោង

- ❖ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ❖ ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
- ❖ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦
- ❖ សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការងារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៩
- ❖ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ❖ ប្រកាស ស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា លេខ ៣០ កយប្រក/០៧ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧
- ❖ សៀវភៅ នីតិវិធី នៃការចាត់ចែងរក្សាការពារ តាក់តែងដោយក្រុមការងារគណៈមេធាវី រួមមាន៖ លោកស្រីមេធាវី មាស ស៊ីថន, លោកមធាវី សួង សុភា, លោកមេធាវី ចៅ ប៊ុនហួន ឆ្នាំ ២០១៧
- ❖ កម្រងឯកសារសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី បញ្ហានានាដែលកើតឡើងនៅក្នុងការអនុវត្តនីតិវិធីចាត់ចែងរក្សាការពារ ភាគទី១ ឧទ្ទេសនាមដោយ៖ លោក ចាយ ច័ន្ទតារា ប្រព្រឹត្តទៅនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៩
- ❖ កម្រងឯកសារសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី បញ្ហានានាដែលកើតឡើងនៅក្នុងការអនុវត្តនីតិវិធីចាត់ចែងរក្សាការពារ ភាគទី២ ឧទ្ទេសនាមដោយ៖ លោក ចាយ ច័ន្ទតារា ប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២០

## **តារាងឧបសម្ព័ន្ធ**

| | |
|---|---|
| **ឧបសម្ព័ន្ធទី១** | ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៧ ការចាត់ចែងរក្សាការពារ ប្រកាសឱ្យប្រើ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ |
| **ឧបសម្ព័ន្ធទី២** | ប្រកាស ស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០ កយ ប្រក/០៧ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧ |
| **ឧបសម្ព័ន្ធទី៣** | ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ |
| **ឧបសម្ព័ន្ធទី៤** | ដីកាសម្រេចរក្សាការពារ |
| **ឧបសម្ព័ន្ធទី៥** | ឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ |
| **ឧបសម្ព័ន្ធទី៦** | ពាក្យសុំអនុវត្តរក្សាការពារ |
| **ឧបសម្ព័ន្ធទី៧** | ពាក្យបណ្តឹងជំទាស់ |